# ព្រឹទ្ធសភា

# *SENATE MAGAZINE*

## ទស្សនាវដ្តីប្រចាំខែឧសភា



លេខ ២៧១ ឆ្នាំទី២៣ ពុទ្ធសករាជ ២៥៦៧ គ្រិស្តសករាជ ២០២៣

Issue 271 Volume 23 Before Christ 2567 Common Era 2023

# មាតិកា

## សកម្មភាពថ្នាក់ដឹកនាំ


- សម្តេចវិបុលសេនាភក្តី សាយ ឈុំ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៤ ...... ១
- ព្រឹទ្ធសភាបន្តសម័យប្រជុំលើកទី១០ ដើម្បីពិនិត្យ ហើយឱ្យយោបល់សេចក្តីព្រាងច្បាប់ចំនួន៣ ...... ២
- សម្តេចប្រធានព្រឹទ្ធសភាទទួលជួបឯកឧត្តមប្រធានរដ្ឋសភានេប៉ាល់ ...... ៥
- សម្តេចប្រធានព្រឹទ្ធសភាទទួលជួបឯកឧត្តមប្រធានរដ្ឋឡាវ ...... ៨
- សម្តេចប្រធានព្រឹទ្ធសភាអញ្ជើញបញ្ចុះខណ្ឌសីមាឆ្លងព្រះវិហារថ្មី និងសម្ពោធសមិទ្ធផលនានាក្នុងវត្តលុម្ពិនីសាលវ័ននារាម ហៅវត្តអូរសោម ...... ១១
- ថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ...... ១៥




## សកម្មភាពគណៈកម្មការ


- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អញ្ជើញសំណេះសំណាលជាមួយអាជ្ញាធរស្រុកត្បូងឃ្មុំ និងក្រុងសួង ខេត្តត្បូងឃ្មុំ ...... ១៦
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ អញ្ជើញសំណេះសំណាលជាមួយអាជ្ញាធរស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ...... ១៨
- គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា ...... ២០
- ការងារទទួលពាក្យបណ្តឹង ...... ២១
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨ ...... ២២
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ...... ៤១




## សកម្មភាពអគ្គលេខាធិការដ្ឋាន


- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមេសា និងទិសដៅការងារខែឧសភា ឆ្នាំ២០២៣ ...... ៤៤
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួងមុខងារសាធារណៈ រៀបចំបាឋកថាស្តីពី ភាពជាអ្នកដឹកនាំ នវានុវត្តន៍ និងគុណាធិបតេយ្យក្នុងរដ្ឋបាលសាធារណៈ ...... ៤៥
- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ ...... ៤៧





**អ្នកគ្រប់គ្រងទូទៅ**
ឯកឧត្តម អ៊ុំ សារិទ្ធ

**អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ**
ឯកឧត្តម លីម ប៊ុនហុក
ឯកឧត្តម កែវ ចាន់ណា
ឯកឧត្តម សុខ រិទ្ធី
ឯកឧត្តម គឹម ពិសិដ្ឋ
ឯកឧត្តម ជួន ណា
លោក ជួន សុខជី
លោក ទេព មករា
លោក កុក រ៉ៃ

**អ្នកគ្រប់គ្រងផ្ទាល់**
លោក ទេព មករា

**ក្រុមអ្នកយកព័ត៌មាន**
ការិយាល័យព័ត៌មាន

**ការីកុំព្យូទ័រ**
លោក ជុំ ច័ន្ទរតនា
លោកស្រី សុខ សុជាតា
លោក គិន ប៉ាត់ថាមីរ


*ក្របមុខ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជាអធិបតីភាពក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមាឆ្លងព្រះវិហារថ្មី ក្នុងវត្តលុម្ពិនីសាលវ័ននារាម ហៅវត្តអូរសោម។*

*ក្របក្រោយ ៖ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូជាន់ខ្ពស់ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។*


**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**
**វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
**ទូរស័ព្ទ: (855) 23 211441, 211442, 211443, ទូរសារ: (855) 23 211446**
**E-mail : oumsarith.sgsenate@gmail.com**
**Website: www.senate.gov.kh**
**www.elibrary.senate.gov.kh**
**Facebook: www.facebook.com/senateofcambodia**

# សម្តេចវិបុលសេនាភក្តី សាយ ឈុំ ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៤



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ ដឹកនាំកិច្ចប្រជុំ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

នាថ្ងៃសុក្រ ទី២៨ ខែមេសា ឆ្នាំ២០២៣ វេលាម៉ោង ៨:០០នាទីព្រឹក ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបៀបវារៈចំនួន៤ រួមមាន៖

**១-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ ស្តីពីសារពើពន្ធ ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី១០ព្រឹទ្ធសភា នីតិកាលទី៤។**

**២-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ ស្តីពីលទ្ធកម្មសាធារណៈ ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី១០ ព្រឹទ្ធសភា នីតិកាលទី៤។**

**៣-ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃព្រឹទ្ធសភា សុំដាក់សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ពាណិជ្ជកម្មតាមព្រំដែនរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី១០ ព្រឹទ្ធសភា នីតិកាលទី៤។**

**៤-កំណត់របៀបវារៈ និងកាលបរិច្ឆេទ បន្តសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤។**

បន្ទាប់ពីបានពិនិត្យ និងពិភាក្សារួចមក គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា បានកំណត់យកថ្ងៃអង្គារ ទី២ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង៨:០០នាទីព្រឹក ដើម្បីបន្តសម័យប្រជុំលើកទី១០ព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីពិនិត្យហើយឱ្យយោបល់សេចក្តីព្រាងច្បាប់ទាំងបីខាងលើ៕

(អត្ថបទ៖ វ៉ាន់ ពិសិដ្ឋ និងរូបភាព៖ គឹម សិទ្ធី)





*ទិដ្ឋភាពកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា*

# ព្រឹទ្ធសភាបន្តសម័យប្រជុំលើកទី១០ ដើម្បីពិនិត្យ ហើយឱ្យយោបល់សេចក្តីព្រាងច្បាប់ចំនួន៣




*សម្តេចវិបុលសេនាភក្តី សាយ ឈុំ ដឹកនាំបន្តសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤*

នាព្រឹកថ្ងៃអង្គារ ទី២ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ៨:០០នាទី ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំលើកទី១០ នីតិកាលទី៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលមានវត្តមានសមាជិកព្រឹទ្ធសភាចំនួន៥៧រូប។

អង្គប្រជុំបានដំណើរការដោយមានរបៀបវារៈចំនួន៣ ដូចខាងក្រោម៖

**របៀបវារៈទី១៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី សារពើពន្ធ។**

សេចក្តីព្រាងច្បាប់នេះ តាក់តែងឡើងក្នុងគោលបំណងដើម្បីធានាបាននូវចីរភាព នៃការកៀរគរប្រមូលចំណូល និងកំណើនសេដ្ឋកិច្ច ការប្រកួតប្រជែងដោយស្មើភាព យុត្តិធម៌ និងសមធម៌សង្គម ព្រមទាំងបន្តលើកកម្ពស់គុណភាព



*ឯកឧត្តម ជា ជេដ្ឋ ឡើងអានរបាយការណ៍ជូនអង្គប្រជុំពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ក្នុងរបៀបវារៈទី១ និងទី២*

សេវាជូនអ្នកជាប់ពន្ធឱ្យមានភាពសាមញ្ញ និងងាយស្រួលក្នុងការបង់ពន្ធ ស្របតាមយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្រ្តកៀរគរចំណូលរបស់រាជរដ្ឋាភិបាល។

សេចក្តីព្រាងច្បាប់នេះ គឺជាឧបករណ៍គតិយុត្តមួយដែលមានលក្ខណៈពេញលេញគ្រប់ជ្រុងជ្រោយ ហើយជាចំណែកមួយយ៉ាងសំខាន់ក្នុងការចូលរួមកែទម្រង់មុតស្រួច និងស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ក្នុងការកៀរគរ និងប្រមូលចំណូលប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពជឿទុកចិត្តបាន ដើម្បីធានាបាននូវចីរភាពកំណើនសេដ្ឋកិច្ច ចីរភាពកំណើនចំណូល ការប្រកួតប្រជែងដោយស្មើភាព យុត្តិធម៌ និងសមធម៌សង្គម ក៏ដូចជាការបង្កើនភាពអនុគ្រោះដល់បរិយាកាសធុរកិច្ច ការអភិវឌ្ឍវិស័យឧស្សាហកម្ម វិស័យសហគ្រាសធុនតូច និងមធ្យម ព្រមទាំងការទាក់ទាញការវិនិយោគរបស់កម្ពុជា ដើម្បីឈានទៅសម្រេចឱ្យបានជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។

សេចក្តីព្រាងច្បាប់នេះតាក់តែងឡើងមាន២០ជំពូក និង២៥៥មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមចំនួន៩៥សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦។

ក្រោយពីសមាជិកព្រឹទ្ធសភាចំនួន៣រូប បានឡើង



*ទិដ្ឋភាពបន្តសម័យប្រជុំលើកទី១០ ព្រឹទ្ធសភានីតិកាលទី៤*

មានយោបល់រួចមក ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្ដីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៥៧សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

**របៀបវារៈទី២៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី លទ្ធកម្មសាធារណៈ។**

សេចក្ដីព្រាងច្បាប់នេះ រៀបចំឡើងក្នុងគោលបំណង ដើម្បីធានាបាននូវភាពជឿទុកចិត្ត តម្លាភាព ប្រសិទ្ធភាព ការប្រកួតប្រជែង និងការសន្សំសំចៃ ព្រមទាំងស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ដោយប្រែក្លាយតួនាទីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅជានិយ័តករ និងសវនកម្មកិច្ចលទ្ធកម្ម ចំណែកស្ថាប័នអនុវត្តលទ្ធកម្មនឹងត្រូវបានផ្ដល់សិទ្ធិអំណាច និងការទទួលខុសត្រូវជាមួយនឹងគណនេយ្យភាពពេញលេញក្នុងការអនុវត្តកិច្ចលទ្ធកម្មរបស់ខ្លួន។

សេចក្ដីព្រាងច្បាប់នេះនឹងក្លាយជាក្របខ័ណ្ឌគតិយុត្តគោលដ៏សំខាន់មួយសម្រាប់ពង្រឹងប្រព័ន្ធលទ្ធកម្មសាធារណៈនៅព្រះរាជាណាចក្រកម្ពុជាលើការគ្រប់គ្រង និងការអនុវត្តកិច្ចលទ្ធកម្មឱ្យកាន់តែមានភាពជឿទុកចិត្ត ប្រសិទ្ធភាព តម្លាភាព ការប្រកួតប្រជែង និងការសន្សំសំចៃ ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ព្រមទាំងរួមចំណែកដល់ការសម្រេចបាននូវទិសដៅ នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលវែង ដើម្បីទ្រទ្រង់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច កំណើនសេដ្ឋកិច្ច និងសមធម៌សង្គម។

សេចក្ដីព្រាងច្បាប់នេះមាន១៥ជំពូក និង៨៧មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមចំនួន៩៤សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦។

ក្រោយពីសមាជិកព្រឹទ្ធសភាចំនួន១រូប បានឡើងមានយោបល់រួចមក ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។



*ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឡើងការពារសេចក្តីព្រាងច្បាប់*

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្ដីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៥៧សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

**របៀបវារៈទី៣៖ ពិនិត្យ ហើយឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពីពាណិជ្ជកម្មតាមព្រំដែនរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គម-**



ឯកឧត្តម គង់ សារាជ ឡើងអានរបាយការណ៍ជូនអង្គប្រជុំ

និយមវៀតណាម។

កិច្ចព្រមព្រៀងស្ដីពី ពាណិជ្ជកម្មតាមព្រំដែនរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម មានគោលបំណងបង្កើតក្របខ័ណ្ឌគតិយុត្ត និងលក្ខខណ្ឌអនុគ្រោះដល់ការធ្វើពាណិជ្ជកម្ម ព្រមទាំងធ្វើឱ្យប្រសើរឡើង និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនតាមព្រំដែន នៃប្រទេសទាំងពីរ។ ការពង្រឹងមិត្តភាព កិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងគ្រប់ជ្រុងជ្រោយ និងការអភិវឌ្ឍប្រកបដោយចីរភាព បង្កើតការតភ្ជាប់ការអភិវឌ្ឍយូរអង្វែង មានស្ថិរភាព និរន្តរភាពសម្រាប់ប្រជាជន នៃប្រទេសទាំងពីរ។

កិច្ចព្រមព្រៀងនេះ នឹងចូលរួមចំណែកក្នុងការអនុវត្តនូវយុទ្ធសាស្ត្រក្នុងការបន្តពង្រឹងការតភ្ជាប់ផ្នែកធុរកិច្ចសំដៅលើកកម្ពស់ការចាប់ដៃគូពាណិជ្ជកម្ម និងការធ្វើពិពិធកម្មទីផ្សារ និងមុខទំនិញនាំចេញតាមរយៈការផ្ដល់ឱកាសការងារ ឱកាសធុរកិច្ចជំរុញផលិតកម្ម និងអាជីវកម្មគ្រួសារ ដែលនឹងជួយជំរុញលើកកម្ពស់ និងធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាជនកម្ពុជានៅតាមព្រំដែនកម្ពុជា-វៀតណាម មានភាពប្រសើរឡើង។

សេចក្ដីព្រាងច្បាប់នេះ តាក់តែងឡើងមាន២មាត្រា ត្រូវបានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា អនុម័តយល់ព្រមចំនួន៩៤សំឡេង នៃចំនួនសមាជិករដ្ឋសភាទាំងមូល នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦។

ក្រោយពីសមាជិកព្រឹទ្ធសភាចំនួន២រូប បានឡើងមានយោបល់រួចមក ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានបំភ្លឺជូនអង្គប្រជុំព្រឹទ្ធសភា។



ឯកឧត្តម ប៉ាន សូរស័ក្តិ ឡើងការពារសេចក្ដីព្រាងច្បាប់

អង្គប្រជុំព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ឯកភាពទាំងស្រុងលើសេចក្ដីព្រាងច្បាប់ទាំងមូលដោយឥតកែប្រែ ចំនួន៥៧សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

(អត្ថបទ៖ ទេព មករា និងរូបភាព៖ គង់ យ៉ារីន)





ទិដ្ឋភាពសមាជិក សមាជិកាព្រឹទ្ធសភា លើកដៃអនុម័តលើសេចក្ដីព្រាងច្បាប់

# សម្ដេចប្រធានព្រឹទ្ធសភាទទួលជួបឯកឧត្ដមប្រធានរដ្ឋសភានេប៉ាល់



*ឯកឧត្ដម ហ្គាណេស ប្រាសាដ ទីមីលស៊ីណា និងសម្ដេចវិបុលសេនាភក្ដី សាយ ឈុំ*

នារសៀលថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ១៥:០០នាទី សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបឯកឧត្ដម **ហ្គាណេស ប្រាសាដ ទីមីលស៊ីណា** (Ganesh Prasad Timilsina) ប្រធានរដ្ឋសភា នៃប្រទេសនេប៉ាល់ នៅវិមានព្រឹទ្ធសភា ក្នុងឱកាសដែលឯកឧត្ដមដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមព្រឹទ្ធសភា និងក្នុងនាមសម្ដេចផ្ទាល់ សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវសេចក្ដីសោមនស្សរីករាយ និងស្វាគមន៍ដ៏កក់ក្ដៅចំពោះឯកឧត្ដម **ហ្គាណេស ប្រាសាដ ទីមីលស៊ីណា** ប្រធានរដ្ឋសភា នៃប្រទេសនេប៉ាល់ និងសមាជិកគណៈប្រតិភូ ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជា។

សម្ដេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះឯកឧត្ដមដែលបានផ្ដល់កិត្តិយសចូលរួមក្នុងពិធីប្រគល់គោរមងារ “ពុទ្ធមាមកាភិបាល នៃអង្គការពុទ្ធសាសនិកពិភពលោក” (The World Fellowship of Buddhist – The WFB) និង“បណ្ឌិតកិត្តិយសផ្នែកមនុស្សសាស្ត្រ” ជូនសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងពិធីប្រគល់គោរមងារជា “ទីប្រឹក្សាជាន់ខ្ពស់” នៃអង្គការពុទ្ធសាសនិកពិភពលោក (WFB) ជូនឯកឧត្ដមបណ្ឌិត **ហ៊ុន ម៉ាណែត**។ ការប្រគល់ជូននូវគោរមងារនេះ គឺជាកិត្តិយសដ៏ឧត្ដុង្គឧត្ដមសម្រាប់ប្រជាជនកម្ពុជាទាំងមូល។

សម្ដេចតេជោនាយករដ្ឋមន្ត្រី ជាឥស្សរជនដ៏គួរឱ្យគោរពស្ញប់ស្ញែង ដោយសម្ដេចបាននាំមកនូវសន្តិភាព ការអភិវឌ្ឍដ៏ខ្លាំងក្លា លើកកម្ពស់សេរីភាពគ្រប់សាសនា លើកគុណតម្លៃមនុស្សជាតិ និងគោរពសិទ្ធិដទៃទៀតស្របតាមគោលការណ៍ជាសកលនៅកម្ពុជា ចាប់តាំងពីឆ្នាំ១៩៧៩ រហូតមកដល់ពេលបច្ចុប្បន្ន។ កម្ពុជាជាប្រទេសដែលមានប្រជាជនគោរពព្រះពុទ្ធសាសនាច្រើនជាង៩០% និងបានចែងក្នុងរដ្ឋធម្មនុញ្ញ ដោយចាត់ទុកសាសនាព្រះពុទ្ធជាសាសនារបស់រដ្ឋ។

ក្នុងឱកាសនោះ ឯកឧត្ដមប្រធានរដ្ឋសភានេប៉ាល់ បានថ្លែងអំណរគុណចំពោះសម្ដេចប្រធានព្រឹទ្ធសភា ដែលបានចំណាយពេលវេលាដ៏មានតម្លៃទទួលជួបគណៈប្រតិភូស្របពេលដែលកម្ពុជាកំពុងមមាញឹកធ្វើជាម្ចាស់ផ្ទះ ក្នុងការរៀបចំការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២។





*ទិដ្ឋភាពរួមក្នុងពិធីជំនួបសវនាការ និងសម្ដែងការគួរសម*



*ទិដ្ឋភាពរួមក្នុងពិធីជំនួបសម្តែងការគួរសម*

ក្នុងនាមរដ្ឋាភិបាលនេប៉ាល់ និងសភានេប៉ាល់ ឯកឧត្តមប្រធានរដ្ឋសភានេប៉ាល់បានថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលស្វាគមន៍យ៉ាងកក់ក្តៅចំពោះគណៈប្រតិភូសភាប្រទេសនេប៉ាល់ ចូលរួមប្រជុំមហាសន្និបាត AIPA លើកទី៤៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះកាលពីខែវិច្ឆិកា ឆ្នាំ២០២២។ ជាមួយគ្នានោះ ឯកឧត្តមបានថ្លែងអំណរគុណចំពោះសភាកម្ពុជា ធ្វើជាម្ចាស់ផ្ទះរៀបចំមហាសន្និបាតអាយប៉ាលើកទី៤៣ កាលពីខែវិច្ឆិកា ឆ្នាំ២០២២កន្លងទៅ ហើយបានគាំទ្រសភានេប៉ាល់ក្លាយជាសមាជិកសង្កេតការណ៍ នៃមហាសន្និបាតអន្តរសភាអាស៊ាន (AIPA)។

ឯកឧត្តមប្រធានរដ្ឋសភានេប៉ាល់បានរំលឹកអំពី ដំណើរទស្សនកិច្ចរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានអញ្ជើញទៅកាន់ប្រទេសនេប៉ាល់កាលពីឆ្នាំ២០១៨ ហើយនៅឆ្នាំ២០១៩ នាយករដ្ឋមន្ត្រី នៃប្រទេសនេប៉ាល់បានអញ្ជើញមកបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជាវិញ។ ការផ្លាស់ប្តូរដំណើរទស្សនកិច្ចទៅវិញទៅមករបស់គណៈប្រតិភូជាន់ខ្ពស់ នៃប្រទេសទាំងពីរ គឺជាការបង្ហាញឱ្យឃើញអំពីការរីកចម្រើន នៃទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ(នេប៉ាល់-កម្ពុជា)។

ឯកឧត្តមប្រធានរដ្ឋសភានេប៉ាល់ បានគាំទ្រឱ្យមានការហោះហើរត្រង់ពីប្រទេសនេប៉ាល់មកប្រទេសកម្ពុជា ដើម្បីនាំមកនូវទេសចរណ៍ និងបង្កើនទំនាក់ទំនងខាងវប្បធម៌ និងសាសនា និងដើម្បីបង្កើនកិច្ចសហប្រតិបត្តិការឱ្យកាន់តែជិតស្និទ្ធថែមទៀតរវាងប្រទេសទាំងពីរ ពីព្រោះថា ប្រទេសទាំងពីរមានអ្នកគោរពប្រតិបត្តិព្រះពុទ្ធសាសនាដូចគ្នា មានវត្តអារាម ប្រាង្គប្រាសាទ និងទីកន្លែងសក្ការៈជាច្រើនសម្រាប់គោរពប្រណិប័តន៍ខាងព្រះពុទ្ធសាសនា។ ទន្ទឹមនឹងនោះ ប្រទេសទាំងពីរត្រូវបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការផ្សេងៗទៀត ដូចជាវិស័យអប់រំ សេដ្ឋកិច្ច វប្បធម៌ ពាណិជ្ជកម្ម និងហិរញ្ញវត្ថុ ដើម្បីរួមចំណែកដល់វិបុលភាពសម្រាប់ប្រទេសទាំងពីរ។

ឆ្លៀតក្នុងឱកាសនោះ ឯកឧត្តមប្រធានរដ្ឋសភានេប៉ាល់បានអញ្ជើញសម្តេចប្រធានព្រឹទ្ធសភា ទៅបំពេញទស្សនកិច្ចនៅប្រទេសនេប៉ាល់ ក្នុងពេលវេលាសមស្របណាមួយ។ ជាមួយគ្នានោះ ឯកឧត្តមបានអបអរសាទរ និងជូនពរប្រទេសកម្ពុជា ឱ្យទទួលបានជោគជ័យក្នុងការរៀបចំការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

សម្តេចប្រធានព្រឹទ្ធសភាបានរំលឹកអំពី ការភ្ជាប់ទំនាក់ទំនងការទូត នៃប្រទេសទាំងពីរតាំងពីឆ្នាំ១៩៦៤ ក្រោមស្នាព្រះហស្ត ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** “ព្រះបរមរតនកោដ្ឋ” និងថ្នាក់ដឹកនាំនេប៉ាល់ជំនាន់មុន។ ដោយសារសង្គ្រាមស៊ីវិលនៅកម្ពុជាទំនាក់ទំនងការទូតនេះត្រូវបានកាត់ផ្តាច់មួយរយៈ ហើយបានភ្ជាប់ទំនាក់ទំនងការទូតឡើងវិញនៅឆ្នាំ១៩៩៩។

សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវសេចក្តីរីករាយចំពោះការរីកចម្រើន នៃទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេស និងប្រជាជនទាំងពីរ។ ទំនាក់ទំនងល្អនេះស្តែងឡើងតាមរយៈការផ្លាស់ប្តូរទស្សនកិច្ចទៅវិញទៅមករបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ នៃប្រទេសទាំងពីរ ការគាំទ្រគ្នា

ទៅវិញទៅមកក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការលើឆាកអន្តរជាតិ ជាពិសេសក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ ដែលបានរួមចំណែកដ៏សំខាន់ដល់សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍក្នុងតំបន់ និងពិភពលោក។

ទន្ទឹមគ្នានោះ សម្ដេចប្រធានព្រឹទ្ធសភាបានរំលឹកអំពីដំណើរទស្សនកិច្ចរបស់សម្ដេចតេជោនាយករដ្ឋមន្ត្រី អញ្ជើញដឹកនាំគណៈប្រតិភូបំពេញទស្សនកិច្ចនៅនេប៉ាល់ នៅឆ្នាំ២០១៨ ដោយបានចុះហត្ថលេខាលើអនុស្សរណៈ-យោគយល់គ្នា និងកិច្ចព្រមព្រៀងសំខាន់ៗរវាងប្រទេសទាំងពីរចំនួន៤លើវិស័យ៖ **១**-ការដឹកជញ្ជូនតាមផ្លូវអាកាស **២**-កិច្ចពិគ្រោះយោបល់ទ្វេភាគីរវាងក្រសួងការបរទេស **៣**-កិច្ចសហប្រតិបត្តិការលើវិស័យវប្បធម៌ និង**៤**-ការលើកលែងទិដ្ឋាការសម្រាប់អ្នកកាន់លិខិតឆ្លងដែនការទូត និងផ្លូវការ ហើយក្នុងឱកាសឯកឧត្ដមនាយករដ្ឋមន្ត្រីនេប៉ាល់ អញ្ជើញដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចជាផ្លូវការនៅកម្ពុជា គឺនៅឆ្នាំ២០១៩ បានចុះហត្ថលេខាលើឯកសារចំនួន២៖ **១**-កិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពី ពាណិជ្ជកម្ម និងវិនិយោគ និង**២**-អនុស្សរណៈនៃការយោគយល់គ្នារវាងសភាពាណិជ្ជកម្មកម្ពុជា និងសភាពាណិជ្ជកម្មនេប៉ាល់។

លិខិតតូបករណ៍ខាងលើនេះ និងយន្តការដែលមានស្រាប់ជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយវឌ្ឍនភាព និងវិបុលភាពរវាងប្រទេសយើងទាំងពីរ ហើយខ្ញុំមានជំនឿជឿជាក់ថា រដ្ឋាភិបាលប្រទេសទាំងពីរនឹងបន្តខិតខំលើកកម្ពស់មិត្តភាពកាន់តែស្និទ្ធស្នាល និងមានផលប្រយោជន៍ទៅវិញទៅមក ក្នុងវិស័យនយោបាយ វប្បធម៌ សេដ្ឋកិច្ច ពាណិជ្ជកម្មវិនិយោគ ទេសចរណ៍ អប់រំ សាសនា និងការផ្លាស់ប្ដូររវាងប្រជាជន និងប្រជាជន។

សម្ដេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណឯកឧត្ដម **ហ្គាណេស ប្រាសាដ ទីមីលស៊ីណា** ដែលបានផ្ដល់នូវពូជស្រូវមកពីទីក្រុងលុម្ពិនី ជាទីកន្លែងកំណើតរបស់ព្រះ-ពុទ្ធ នេះគឺជាការតភ្ជាប់វប្បធម៌ដ៏សំខាន់រវាងប្រទេសយើងទាំងពីរដែលគាំទ្រដល់ការអនុវត្តស្មារតី នៃអនុស្សរណៈ-យោគយល់គ្នាផ្នែកវប្បធម៌។

សម្ដេចប្រធានព្រឹទ្ធសភាបានអបអរសាទរប្រទេសនេ-ប៉ាល់ ដែលត្រូវបានកិច្ចប្រជុំពេញអង្គលើកទី៤០ នៃសម័យប្រជុំលើកទី៧៦ របស់មហាសន្និបាតអង្គការសហប្រជា-ជាតិ បានអនុម័តលើសំណើដំឡើងចំណាត់ថ្នាក់ប្រទេសនេប៉ាល់ទៅជាប្រទេសកំពុងអភិវឌ្ឍន៍ដែលមានចំណូលមធ្យមនៅឆ្នាំ២០២៦។

សម្ដេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណឯកឧត្ដមប្រធានរដ្ឋសភានេប៉ាល់ ដែលបានដឹកនាំគណៈប្រតិភូចូល-រួមមហាសន្និបាត AIPA លើកទី៤៣ នៅព្រះរាជាណាចក្រ-កម្ពុជា។ ជាមួយគ្នានោះ សម្ដេចបានសម្ដែងការអបអរ-សាទររដ្ឋសភានេប៉ាល់ដែលបានក្លាយជាសមាជិកសង្កេត-ការណ៍ នៃមហាសន្និបាតអន្តរសភាអាស៊ាន (អាយប៉ា) ក្នុងឱកាសដែលសភាកម្ពុជាធ្វើជាម្ចាស់ផ្ទះរៀបចំមហាសន្និ-បាតអាយប៉ាលើកទី៤៣ កាលពីខែវិច្ឆិកា ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ។

សម្ដេចប្រធានព្រឹទ្ធសភាបានស្នើឱ្យមានកិច្ចសហប្រតិ-បត្តិការកាន់តែជិតស្និទ្ធរវាងព្រឹទ្ធសភាកម្ពុជា ជាមួយនឹងរដ្ឋសភានេប៉ាល់ ដោយជំរុញឱ្យមានការផ្លាស់ប្ដូរទស្សនកិច្ចគ្នាទៅវិញទៅមកគ្រប់កម្រិត និងបង្កើតក្រុមមិត្តភាពទ្វេភាគីរដ្ឋសភានេប៉ាល់ជាមួយនឹងព្រឹទ្ធសភាកម្ពុជា ព្រមទាំងគាំទ្រគ្នាទៅវិញទៅមកក្នុងក្របខ័ណ្ឌអន្តរសភា ដូចជា IPU, AIPA, APPF និង APA។

ឆ្លើយតបនឹងការអញ្ជើញសម្ដេចទៅបំពេញទស្សនកិច្ចនៅប្រទេសនេប៉ាល់ សម្ដេចប្រធានព្រឹទ្ធសភាបានទទួលយកសំណើនេះ និងរកពេលវេលាសមស្របណាមួយ ដើម្បីអញ្ជើញទៅបំពេញទស្សនកិច្ច។

សម្ដេចប្រធានព្រឹទ្ធសភាបានប្រសិទ្ធពរជូនគណៈប្រតិភូមានសុខភាពល្អ និងទទួលបានជោគជ័យថ្មីៗក្នុងឱកាសស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា៕

(អត្ថបទ៖ នុត សច្ចៈ និងរូបភាព៖ គង់ យ៉ារីន)



*សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ថតរូបអនុស្សាវរីយ៍ជាមួយ ឯកឧត្ដម ហ្គាណេស ប្រាសាដ ទីមីលស៊ីណា ប្រធានរដ្ឋសភានេប៉ាល់*

# សម្តេចប្រធានព្រឹទ្ធសភាទទួលជួបឯកឧត្តមប្រធានរដ្ឋឡាវ



*ឯកឧត្តម ថងលុន ស៊ីសុលីត និងសម្តេចវិបុលសេនាភក្តី សាយ ឈុំ*

នារសៀលថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ១៤:១០ នាទី នៅវិមានព្រឹទ្ធសភា សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលជួបសវនាការជាមួយនឹងឯកឧត្តម **ថងលុន ស៊ីសុលីត** ប្រធានរដ្ឋ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងឱកាសដែលឯកឧត្តមប្រធានរដ្ឋឡាវ ដឹកនាំគណៈប្រតិភូជាន់ខ្ពស់ អញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា និងអញ្ជើញចូលរួមពិធីបើកជាផ្លូវការកីឡាអាស៊ីអាគ្នេយ៍លើកទី៣២។

ក្នុងនាមប្រជាជនកម្ពុជា ព្រឹទ្ធសភា និងក្នុងនាមសម្តេចផ្ទាល់ សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវការស្វាគមន៍ដ៏កក់ក្តៅបំផុតចំពោះឯកឧត្តមប្រធានរដ្ឋឡាវ ដែលបានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ អញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា និងអញ្ជើញចូលរួមពិធីបើកជាផ្លូវការកីឡាអាស៊ីអាគ្នេយ៍លើកទី៣២។ ទស្សនកិច្ចផ្លូវរដ្ឋរបស់ឯកឧត្តមនៅព្រះរាជាណាចក្រកម្ពុជាមានអត្ថន័យប្រវត្តិសាស្ត្រ បន្តថែរក្សាពូនជ្រំចំណងមិត្តភាព សាមគ្គីភាព កិច្ចសហប្រតិបត្តិការរវាងប្រទេស និងប្រជាជនទាំងពីរ ដែលមានជាយូរលង់មកហើយឱ្យកាន់តែរឹងមាំស៊ីជម្រៅថែមទៀត ហើយនាំមកនូវផលប្រយោជន៍ដ៏ធំធេងទៅវិញទៅមក សម្រាប់ប្រទេសទាំងពីរ ទាំងពេលបច្ចុប្បន្ន និងពេលអនាគត។

ជាមួយគ្នានោះ សម្តេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណចំពោះឯកឧត្តមប្រធានរដ្ឋឡាវ ដែលបានផ្តល់កិត្តិយសអញ្ជើញចូលរួមក្នុងពិធីបើកការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ (ស៊ីហ្គេម) ក្រោមមូលបទ “កីឡារស់ក្នុងសន្តិភាព» និងបានបញ្ជូនប្រតិភូកីឡាឡាវចំនួន៦៥៦នាក់មកចូលរួមក្នុងស្មារតីសាមគ្គីភាព និងមិត្តភាព។ សម្តេចបានសម្តែងនូវសុទិដ្ឋិនិយមថា កីឡាករឡាវនឹងទទួលបានជ័យជម្នះក្នុងវិញ្ញាសាកីឡាមួយចំនួន។

ក្នុងឱកាសនោះ ឯកឧត្តមប្រធានរដ្ឋឡាវបានថ្លែងអំណរគុណចំពោះសម្តេចប្រធានព្រឹទ្ធសភា ដែលបានទទួលជួបគណៈប្រតិភូ។ ឯកឧត្តមបានពាំនាំនូវការសួរសុខទុក្ខពីសំណាក់ឯកឧត្តមប្រធានរដ្ឋសភាឡាវ ជូនចំពោះសម្តេចប្រធានព្រឹទ្ធសភា។

ឯកឧត្តមប្រធានរដ្ឋឡាវបានបញ្ជាក់ថា ក្នុងឋានៈជាប្រធានរដ្ឋ នេះជាលើកទី១ហើយដែលឯកឧត្តមបានអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែក្នុងតួនាទីផ្សេងៗ ឯកឧត្តមបានអញ្ជើញមកបំពេញទស្សនកិច្ចនៅកម្ពុជាជាច្រើនលើករួចមកហើយតាមរយៈ





*ទិដ្ឋភាពរួមក្នុងពិធីជំនួបសម្តែងការគួរសម*



ទិដ្ឋភាពរួមក្នុងពិធីជំនួបសម្ដែងការគួរសម

ដំណើរទស្សនកិច្ចនាពេលកន្លងទៅ ក៏ដូចជានាពេលនេះ។ ឯកឧត្ដមប្រធានរដ្ឋឡាវសូមសម្ដែងនូវការអបអរសាទរ និងវាយតម្លៃខ្ពស់ចំពោះការអភិវឌ្ឍរីកចម្រើនជាបន្ដបន្ទាប់ និងជាជំហានៗរបស់ប្រទេសកម្ពុជា ដែលបានធ្វើឱ្យសេដ្ឋកិច្ចសង្គមមានការអភិវឌ្ឍ ប្រជាជនមានជីវភាពរស់នៅល្អប្រសើរក្រោមព្រះរាជដឹកនាំរបស់ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្ដម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងក្រោមការដឹកនាំរបស់ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាលកម្ពុជា។

ឯកឧត្ដមប្រធានរដ្ឋឡាវបានសម្ដែងនូវការអបអរសាទរចំពោះសភាកម្ពុជា ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល ជាពិសេសអង្គការនីតិប្បញ្ញត្តិ នៃប្រទេសទាំងពីរ(ឡាវ-កម្ពុជា)។

ឯកឧត្ដមប្រធានរដ្ឋឡាវបានជម្រាបជូនសម្ដេចប្រធានព្រឹទ្ធសភាជ្រាបអំពីលទ្ធផល នៃជំនួបរវាងឯកឧត្ដមជាមួយនឹងព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ដ្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយទទួលបានលទ្ធផលយ៉ាងត្រចះត្រចង់ ជាពិសេសការលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាប្រពៃណីជួយគ្នា ហើយនឹងថែរក្សាប្រពៃណីដ៏ល្អនេះ ឱ្យកាន់តែមានផ្លែផ្កាល្អប្រសើរជាងនេះថែមទៀត។

ជាមួយគ្នានោះ ឯកឧត្ដមសង្ឃឹមថា ព្រឹទ្ធសភាកម្ពុជានឹងបន្តគាំទ្រដល់ការពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល នៃប្រទេសទាំងពីរ។

ឯកឧត្ដមប្រធានរដ្ឋឡាវបានរំលឹកអំពីដំណើរទស្សនកិច្ចរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ទៅកាន់ប្រទេសឡាវកាលពីពេលថ្មីៗនេះ ហើយថ្នាក់ដឹកនាំនៃប្រទេសទាំងពីរបានឯកភាពគ្នាចំពោះការបោះបង្គោលព្រំដែនរវាងប្រទេសទាំងពីរដែលសម្រេចបាន៨៦% ហើយនឹងបន្តការងារនេះឱ្យបានជោគជ័យថែមទៀតក្នុងពេលដ៏ខ្លីខាងមុខ។ នេះជាបុព្វហេតុដ៏មានសារៈសំខាន់ណាស់ ដើម្បីធ្វើឱ្យខ្សែបន្ទាត់ព្រំដែនប្រទេសទាំងពីរ មានស្ថិរភាព និងទុកជាកេរមរតកដល់មនុស្សជំនាន់ក្រោយ។

ឯកឧត្ដមប្រធានរដ្ឋឡាវបានសម្ដែងនូវការអបអរសាទរ និងជូនពរប្រទេសកម្ពុជា សូមទទួលបានជោគជ័យក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២។

ជាមួយគ្នានោះ សម្ដេចប្រធានព្រឹទ្ធសភាបានសម្ដែងនូវសេចក្ដីសប្បាយរីករាយជាអតិបរមា ដោយមើលឃើញចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរ មានការរីកចម្រើនលើគ្រប់វិស័យ ហើយត្រូវបានលើកកម្រិតទំនាក់ទំនងជា “ដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងយូរអង្វែង”។ ប្រជាជន រដ្ឋាភិបាល នៃប្រទេសទាំងពីរ នឹងបន្តពង្រឹង និងពង្រីកនូវទំនាក់ទំនង សាមគ្គីភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការឱ្យបានរឹងមាំខ្លាំងក្លាថែមទៀត ដើម្បីជាគុណប្រយោជន៍ដ៏ធំធេងសម្រាប់ប្រទេសជាតិទាំងពីរ ទាំងក្នុងពេលបច្ចុប្បន្ន និងទៅអនាគត។

សម្ដេចប្រធានព្រឹទ្ធសភាបានជម្រាបជូនឯកឧត្ដមប្រធានរដ្ឋឡាវជ្រាបថា ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាបានប្រោសប្រទានព្រះរាជក្រមផ្ដល់សច្ចាប័នលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ រួចហើយ។ សម្ដេច

សង្ឃឹមយ៉ាងមុតមាំថា រដ្ឋាភិបាល នៃប្រទេសទាំងពីរនឹងខិតខំអនុវត្តនូវកិច្ចព្រមព្រៀងនេះ ដើម្បីឈានទៅសម្រេចឱ្យបាននូវការបោះបង្គោលព្រំដែនទាំងស្រុង ដើម្បីប្រែក្លាយព្រំដែន នៃប្រទេសទាំងពីរឱ្យទៅជាព្រំដែនមិត្តភាព សន្តិភាព និងសហប្រតិបត្តិការ ដើម្បីទុកជាមរតកដ៏ថ្លៃថ្លាសម្រាប់កូនចៅទាំងជំនាន់នេះ និងទៅជំនាន់តទៅមុខទៀត។

សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវមនោសញ្ចេតនាសប្បាយរីករាយ និងអបអរសាទរចំពោះការសម្រេចបាននូវសមិទ្ធផលសង្គម-សេដ្ឋកិច្ចរបស់សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាព។ សម្តេចមានជំនឿជឿជាក់ថា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់បក្សប្រជាជនបដិវត្តន៍ឡាវ និងថ្នាក់ដឹកនាំឡាវ ប្រទេសឡាវនឹងទទួលបានជោគជ័យឧត្តុង្គឧត្តមធំធេងបន្ថែមទៀតក្នុងការអនុវត្តផែនការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចសម្រាប់ឆ្នាំ២០២១-២០២៥ ដើម្បីនាំមកនូវសុភមង្គល វិបុលភាព និងភាពសម្បូររុងរឿងជូនប្រជាជនឡាវ និងសម្រេចបាននូវបំណងប្រាថ្នាក្លាយជាប្រទេស ដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ ២០៣០។

សម្តេចប្រធានព្រឹទ្ធសភាបានសម្តែងនូវការអបអរសាទរចំពោះសភា នៃប្រទេសទាំងបី(កម្ពុជា-ឡាវ-វៀតណាម ) បានសម្រេចដំឡើងកម្រិត នៃកិច្ចប្រជុំតំបន់ត្រីកោណអភិវឌ្ឍន៍ពីកម្រិតគណៈកម្មការកិច្ចការបរទេសទៅជាកម្រិតថ្នាក់ដឹកនាំសភា។ ជាមួយគ្នានោះ សម្តេចបានវាយតម្លៃខ្ពស់ចំពោះសភា នៃប្រទេសទាំងពីរ ដែលមានទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយគ្នាយ៉ាងល្អ និងបានខិតខំយកចិត្តទុកដាក់ខ្ពស់រួមចំណែកថែរក្សាពូនជ្រំទំនាក់ទំនងប្រទេសទាំងពីរ សភាទាំងពីរ តាមរយៈការផ្លាស់ប្តូរទស្សនកិច្ចរវាងថ្នាក់ដឹកនាំ សមាជិកសភា ក្រុមមិត្តភាពសភាទ្វេភាគី និងរបស់ក្រុម CLV ទៅវិញទៅមក ហើយបានគាំទ្រគ្នាទៅវិញទៅមកនៅក្នុងក្របខ័ណ្ឌអន្តរសភា រួមមាន៖ AIPA, APF APPF, ASEP និង IPU ។

សម្តេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា នាពេលកន្លងទៅ ព្រឹទ្ធសភាតែងតែគាំទ្រ និងលើកទឹកចិត្តទាំងស្រុងនូវរាល់កិច្ចព្រមព្រៀង និងអនុស្សរណៈយោគយល់គ្នារវាងប្រទេសទាំងពីរ ហើយលើកទឹកចិត្តឱ្យរដ្ឋាភិបាល នៃប្រទេសទាំងពីរខិតខំអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាព។ កម្ពុជាជានិច្ចកាលចាត់ទុកប្រទេសឡាវជាដៃគូល្អ ជាមិត្តល្អ ជាបងប្អូនល្អ និងជាអ្នកជិតខាងល្អ ហើយត្រៀមគ្រប់លក្ខណសម្បត្តិបន្តជួយគាំទ្រគ្នាទៅវិញទៅមកក្នុងពេលបច្ចុប្បន្ន ក៏ដូចជាពេលអនាគត។

ក្នុងឱកាសនោះ សម្តេចប្រធានព្រឹទ្ធសភាបានថ្លែងអំណរគុណចំពោះឯកឧត្តមប្រធានរដ្ឋសភាដែលបានផ្តាំផ្ញើនូវការសួរសុខទុក្ខចំពោះសម្តេច ហើយតាមរយៈឯកឧត្តមប្រធានរដ្ឋឡាវ សម្តេចបានផ្តាំផ្ញើការសួរសុខទុក្ខ និងជូនពរជូនចំពោះឯឧត្តមប្រធារដ្ឋសភាឡាវវិញផងដែរ។

សម្តេចប្រធានព្រឹទ្ធសភាបានប្រសិទ្ធពរជូនគណៈប្រតិភូមានសុខភាពល្អ មានសេចក្តីរីករាយ និងទទួលបានជោគជ័យថ្មីៗ ក្នុងឱកាសស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា ព្រមទាំងប្រសិទ្ធពរចំពោះចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរមានការរីកចម្រើនឡើងជារៀងរហូត៕

(អត្ថបទ៖ វ៉ាន់ ពិសិដ្ឋ និងរូបភាព៖ គង់ យ៉ារីន)



*សម្តេចវិបុលសេនាភក្តី សាយ ឈុំ ថតរូបអនុស្សាវរីយ៍ជាមួយគណៈប្រតិភូជាន់ខ្ពស់ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ*

# សម្តេចប្រធានព្រឹទ្ធសភាអញ្ជើញបញ្ចុះខណ្ឌសីមាឆ្លងព្រះវិហារថ្មី និងសម្ពោធសមិទ្ធផលនានាក្នុងវត្តលុម្ពិនីសាលវ័ននារាម ហៅវត្តអូរសោម





សម្តេចប្រធានព្រឹទ្ធសភា អញ្ជើញកាត់ខ្សែបូសម្ពោធសមិទ្ធផលនានា និងកាត់ឫសសីមាឆ្លងព្រះវិហារថ្មី ក្នុងវត្តលុម្ពិនីសាលវ័ននារាម ហៅវត្តអូរសោម

ព្រះវិហារថ្មី និងសមិទ្ធផលនានាក្នុងវត្តលុម្ពិនីសាលវ័ននារាម ហៅវត្តអូរសោម ស្ថិតក្នុងឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ ត្រូវបានប្រារព្ធពិធីបញ្ចុះខណ្ឌសីមា និងសម្ពោធដាក់ឱ្យប្រើប្រាស់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្ដី **សាយ ឈុំ** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នាព្រឹកថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០២៣ ដោយមានការអញ្ជើញចូលរួមពីសមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ទីប្រឹក្សា ថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ នៃខេត្តពោធិ៍សាត់ និងពុទ្ធបរិស័ទចំណុះជើងវត្តយ៉ាងច្រើនកុះករ។

ក្នុងឱកាសនោះ ឯកឧត្តម **ខូយ រីដា** អភិបាល នៃគណៈអភិបាលខេត្តពោធិ៍សាត់ បានជម្រាបជូនអង្គពិធីជ្រាបថា វត្តលុម្ពិនីសាលវ័ននារាម ជាវត្តមួយក្នុងចំណោមវត្តទាំង ២៣ ក្នុងស្រុកវាលវែង។ វត្តនេះមានផ្ទៃដីសរុប៨.៦៦០៣ ម៉ែត្រការ៉េ បច្ចុប្បន្នមានព្រះសង្ឃគង់នៅចំនួន៤អង្គ ភិក្ខុ ២អង្គ សាមណេរ២អង្គ គណៈកម្មការវត្តមាន១២នាក់។ វត្តលុម្ពិនីសាលវ័ននារាម ត្រូវបានកសាងឡើងនៅថ្ងៃទី១ ខែមករា ឆ្នាំ២០០៨។ កាលពីចាប់ផ្តើមកសាងដំបូងសមិទ្ធផលក្នុងវត្តមានដូចជា បង្គន់អនាម័យ៣ខ្នងមាន៥បន្ទប់ កុដិ៥ខ្នង ស្មើ១១បន្ទប់ ខ្លោងទ្វារចំនួន១ និងរបងចំនួន៨៣ ផ្ទាំងដោយក្នុង១ផ្ទាំងទំហំ២,៥ម៉ែត្រគុណ៣,៥ម៉ែត្រ។ នៅឆ្នាំ២០១៧ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា មានសទ្ធាជ្រះថ្លាផ្តួចផ្តើមកសាងសាលាឆាន់១ខ្នងទំហំ២០ម៉ែត្រគុណ១២ម៉ែត្រ និងបានសាងសង់រួចរាល់នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៨។



សម្តេចប្រធានព្រឹទ្ធសភា អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា និងសម្ពោធសមិទ្ធផលនានា




*ឯកឧត្តម ខូយ រីដា អភិបាល នៃគណៈអភិបាលខេត្តពោធិ៍សាត់ ឡើងអានរបាយការណ៍ជូនអង្គពិធី*

បច្ចុប្បន្នឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ខុន** អនុប្រធានទី២ព្រឹទ្ធសភា ដោយមានការចូលរួមកសាងដោយឯកឧត្តម **ប្រាក់ ចំរើន** និងលោកជំទាវ ព្រមទាំងបុត្រ រួមជាមួយនឹងឯកឧត្តម **ទេព ធន** រដ្ឋលេខាធិការក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងលោកជំទាវ ព្រមទាំងបុត្រ និងឯកឧត្តម **សន លីវណ្ណា** ទីប្រឹក្សាឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ខុន** បានកសាងព្រះវិហារទំហំ៩,២០ម៉ែត្រ គុណនឹង១៤,៦០ម៉ែត្រ ដែលត្រូវចាប់ផ្តើមកសាងនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ និងបានបញ្ចប់ការកសាងនៅថ្ងៃព្រហស្បតិ៍ ទី២៣ ខែមីនា ឆ្នាំ២០២៣ ដោយចំណាយថវិកាសរុបអស់ចំនួន១៦៧.៦០០ដុល្លារអាមេរិក។

ក្នុងឱកាសដ៏មហោឡារិកនោះ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** បានសម្តែងនូវសេចក្តីរីករាយដោយបានមកកាន់វត្តលុម្ពិនីសាលវ័ននារាមនេះជាលើកទី២។ ពិធីបញ្ចុះខណ្ឌសីមាព្រះវិហារថ្មី និងសម្ពោធដាក់ឱ្យប្រើប្រាស់នូវសមិទ្ធផលនានាក្នុងវត្តលុម្ពិនីសាលវ័ននារាម ហៅវត្តអូរសោម បាននឹងកំពុងប្រព្រឹត្តទៅយ៉ាងរលូន ឱឡារិក និងអធិកអធមយ៉ាងក្រៃលែង ស្របពេលដែលប្រជាជនកម្ពុជាយើងទូទាំងប្រទេសបានប្រារព្ធនូវពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ប្រកបដោយបរិយាកាសសប្បាយរីករាយក្រោមម្លប់សន្តិភាព និងស្របពេលដែលការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៃរដ្ឋសភា នីតិកាលទី៧ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ កាន់តែខិតជិតមកដល់។

តាមរយៈសេចក្តីរាយការណ៍របស់ឯកឧត្តមអភិបាលខេត្តពោធិ៍សាត់ សម្តេចប្រធានព្រឹទ្ធសភាបានអបអរសាទរ និងវាយតម្លៃខ្ពស់ចំពោះគណៈអភិបាលខេត្តពោធិ៍សាត់ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ព្រះសង្ឃ ព្រមទាំងប្រជាពលរដ្ឋទាំងអស់ដែលកន្លងមកក៏ដូចជាបច្ចុប្បន្នបាននឹងកំពុងអនុវត្តន៍យ៉ាងសកម្មនូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្នុងគ្រប់ដំណាក់កាលទទួលបានជោគជ័យជាបន្តបន្ទាប់ ធ្វើឱ្យខេត្តពោធិ៍សាត់មានការរីកចម្រើន ប្រែមុខប្រែមាត់ថ្មីស្រឡាងពីមួយឆ្នាំទៅមួយឆ្នាំទាំងផ្នែកអាណាចក្រ និងពុទ្ធចក្រគួរជាទីមោទនភាពយ៉ាងក្រៃលែង។

សម្តេចប្រធានព្រឹទ្ធសភាបានរំលឹកពីអតីតកាលដែលប្រជាជនកម្ពុជាមិនអាចបំភ្លេចបានកាលពីទសវត្សរ៍ឆ្នាំ៧០ ព្រះពុទ្ធសាសនាត្រូវបានអាប់ឱនដោយសារសង្គ្រាម និងត្រូវបានកម្ទេចដោយរបបប្រល័យពូជសាសន៍ប៉ុលពត។




*ទិដ្ឋភាពប្រជាពលរដ្ឋចូលរួមក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា និងសម្ពោធសមិទ្ធផលនានា*

ព្រះពុទ្ធសាសនាត្រូវបានរស់ឡើងវិញព្រមគ្នាជាមួយនឹងការរស់ឡើងវិញរបស់ប្រទេសជាតិ និងប្រជាជនកម្ពុជាកាលពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ តាំងពីពេលនោះរហូតមកដល់បច្ចុប្បន្ន វិស័យព្រះពុទ្ធសាសនាត្រូវបានស្ដារ និងអភិវឌ្ឍឡើងវិញយ៉ាងឆាប់រហ័ស ទាំងបរិមាណ និងគុណភាព ហើយកំពុងក្លាយជាកម្លាំងស្នូល នៃសុខដុមនីយកម្មរវាងអ្នកកាន់ព្រះពុទ្ធសាសនា ជាមួយនឹងអ្នកកាន់ជំនឿ និងសាសនាផ្សេងៗទៀត ដែលកំពុងមានវត្តមាននៅកម្ពុជាបច្ចុប្បន្ន។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ថា លទ្ធិព្រះពុទ្ធសាសនាបានចាក់ឫសយ៉ាងជ្រៅទៅក្នុងក្រអៅបេះដូងរបស់ប្រជាជនកម្ពុជា។ ប្រជាពុទ្ធបរិស័ទ លោកយកព្រះពុទ្ធសាសនាជាទីពឹង ដើម្បីស្វែងរកសេចក្ដីសុខ សេចក្ដីចម្រើនទាំងក្នុងបច្ចុប្បន្នជាតិ និងក្នុងអនាគតជាតិ។ ព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ គឺជាទឹកអម្រិតដែលជនានុជនគ្រប់រូបប្រាថ្នាចង់បានគ្រប់ៗគ្នា។ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់យ៉ាងច្បាស់ថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ហើយចារឹកជាបាវចនារបស់ប្រទេសជាតិ(ជាតិ សាសនា ព្រះមហាក្សត្រ)ហើយក្នុងបទចម្រៀងគោរពទង់ជាតិរបស់យើងក៏រំលេចខ្លឹមសារនឹកដល់គុណព្រះពុទ្ធសាសនាផងដែរ។

សម្ដេចប្រធានព្រឹទ្ធសភាបានបញ្ជាក់ផងដែរថា បច្ចុប្បន្នក៏ដូចជាទៅអនាគត រាជរដ្ឋាភិបាលកម្ពុជាបន្តអនុវត្តដោយខ្ជាប់ខ្ជួនក្នុងការគោរពសេរីភាពខាងជំនឿ ការប្រណិប័តន៍ខាងផ្លូវសាសនា លើកស្ទួយព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ និងគាំទ្រការប្រណិប័តន៍សាសនាផ្សេងៗទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការខិតខំធ្វើឱ្យវត្តអារាម និងវិហារសាសនាឯទៀតៗ ក្លាយជាមជ្ឈមណ្ឌល នៃជីវភាពខាងស្មារតី ដែលចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសង្គមជាតិ ខាងផ្នែកវប្បធម៌ អប់រំ សុខាភិបាល សង្គមកិច្ច និងសីលធម៌សង្គម។ ពង្រឹងសុខដុមនីយកម្មរវាងគ្រប់សាសនានៅក្នុងព្រះរាជាណាចក្រកម្ពុជា ទប់ស្កាត់ការធ្វើអាជីវកម្មលើសាសនា ប្រឆាំងការរើសអើងបែងចែករវាងប្រជាជន និងប្រជាជន ដែលបណ្ដាលមកពីភាពខុសគ្នាខាងជំនឿ និង



*សម្ដេចប្រធានព្រឹទ្ធសភាអញ្ជើញឡើងថ្លែងសុន្ទរកថាក្នុងអង្គពិធី*

សាសនាសំដៅប្រែក្លាយសក្ដានុពលរបស់សាសនាទាំងអស់ទៅជាកម្លាំងសាមគ្គីមួយដ៏ខ្លាំងក្លាក្នុងការការពារសន្តិភាព ឯកភាពជាតិ និងជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ ពង្រឹងការអប់រំពុទ្ធិកសិក្សាពីកម្រិតបឋមសិក្សាទៅកម្រិតឧត្ដមសិក្សា និងក្រោយឧត្ដមសិក្សា។ ថែរក្សាមរតកប្រពៃណីទំនៀមទម្លាប់ក្នុងវិស័យពុទ្ធចក្រ បណ្ដុះបណ្ដាលធនធានមនុស្សក្នុងវិស័យសាសនា បណ្ដុះបណ្ដាលធនធានព្រះសង្ឃប្រកបដោយចំណេះដឹង ជំនាញ និងគុណធម៌ ប្រកាន់ក្រឹត្យវិន័យតាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត។ គិតមកដល់បច្ចុប្បន្ននេះ នៅទូទាំងព្រះរាជាណាចក្រកម្ពុជាយើង មានវត្តព្រះពុទ្ធសាសនាចំនួន៥.១០៤វត្ត ព្រះសង្ឃ៧០.៩០៥អង្គ ក្នុងនោះមានសមណសិស្ស សមណនិស្សិត និងសិស្សនិស្សិតបាននឹងកំពុងរៀននៅតាមពុទ្ធិកសិក្សាគ្រប់កម្រិតទាំងអស់ចំនួន៤៥.២៥៤អង្គ/នាក់។ ទាំងអស់នេះគឺជាសក្ខីកម្មបង្ហាញយ៉ាងច្បាស់ណាស់ថា បច្ចុប្បន្នវិស័យព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាយើងបាននឹងកំពុងរីកចម្រើនយ៉ាងខ្លាំងក្លាទាំងបរិមាណ និងគុណភាព។

ដោយឡែកខាងវិស័យអាណាចក្រ រាជរដ្ឋាភិបាលបាននឹងកំពុងថែរក្សានិងការពារសន្តិភាព ឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពបានយ៉ាងគត់ម៉ត់ក្នុងគ្រប់ស្ថានភាព និងកាលៈទេសៈទាំងអស់ បានប្រយុទ្ធប្រឆាំង និងគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ-១៩យ៉ាងមានប្រសិទ្ធភាព ហើយបាននឹងកំពុងដឹកនាំប្រយុទ្ធស្ដារ និងអភិវឌ្ឍប្រទេសពីវិបត្តិកូវីដ-១៩ យ៉ាងសស្រាក់សស្រាំធ្វើឱ្យកំណើន




*ទិដ្ឋភាពប្រជាពលរដ្ឋចូលរួមក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា និងសម្ពោធសមិទ្ធផលនានា*

សេដ្ឋកិច្ចដែលបានធ្លាក់ចុះរហូតដល់៣,១% នៅឆ្នាំ២០២០ មកកាន់កំណើន ៥,៤% នៅឆ្នាំ២០២២ ហើយតាមការព្យាករណ៍កម្ពុជាអាចសម្រេចបាននូវកំណើនសេដ្ឋកិច្ច ៥,៦% នៅឆ្នាំ២០២៣។ រាជរដ្ឋាភិបាលបាននឹងកំពុងជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកាន់តែសកម្មជាងនេះទៀត ដើម្បីឈានទៅសម្រេចនូវចក្ខុវិស័យប្រែក្លាយកម្ពុជាជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ ក្រោមពាក្យស្លោក អរគុណសន្តិភាព អរគុណនយោបាយឈ្នះ-ឈ្នះ ដឹងគុណស្ថាបនិកមគ្គុទេសក៍ឯក និងប្រតិបត្តិករនយោបាយឈ្នះ-ឈ្នះ មានសន្តិភាពទើបមានការអភិវឌ្ឍនិងមានអ្វីៗទាំងអស់ បានក្លាយជាស្មារតីសង្គមដ៏ខ្លាំងក្លា និងក្លាយជាចលករការពារសន្តិភាព ការពារសមិទ្ធផលសង្គមជាតិ និងដំណើរឈានទៅមុខរបស់ប្រទេសជាតិយ៉ាងសស្រាក់សស្រាំ។

ឈរលើមូលដ្ឋាននេះ កម្ពុជាត្រូវបានវាយតម្លៃថា ជាប្រទេសដែលគ្រប់គ្រងការរីករាលដាល នៃជំងឺកូវីដ-១៩ បានយ៉ាងល្អប្រពៃ ហើយត្រូវបានទទួលស្គាល់ថា ជាប្រទេសឈរនៅលំដាប់លេខ២ក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ របស់ពិភពលោក និងជាប្រទេសដែលសម្រេចបាននូវវឌ្ឍនភាពដ៏ល្អប្រសើរក្នុងការលើកកម្ពស់ជីវភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនបានយ៉ាងឆាប់រហ័ស។ កាលពីខែវិច្ឆិកា ឆ្នាំ២០២២ កន្លងទៅថ្មីៗ កម្ពុជាបានសម្រេចនូវសមិទ្ធផលប្រវត្តិសាស្ត្រដ៏លេចធ្លោក្នុងនាមជាប្រធានប្តូរវេនរបស់អាស៊ាន ដោយបានរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០-៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធយ៉ាងរលូន និងប្រកបដោយលទ្ធផលជាផ្លែផ្កាយ៉ាងត្រចះត្រចង់។ រយៈពេលកន្លងទៅក៏ដូចជាបច្ចុប្បន្ន ប្រទេសកម្ពុជាក្រោមការដឹកនាំដ៏ត្រឹមត្រូវ ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សម្រេចបាននូវសមិទ្ធផលយ៉ាងធំធេងទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រដែលធ្វើឱ្យកិត្យានុភាពរបស់កម្ពុជាលេចឡើងយ៉ាងខ្ពស់លើឆាកអន្តរជាតិ និងជាមូលដ្ឋានឱ្យឈោងឈានទៅសម្រេចជោគជ័យធំៗ និងថ្មីៗជាច្រើនទៀត ក្នុងការកសាង និងការពារប្រទេសឱ្យកាន់តែខ្លាំងក្លារុងរឿងនាពេលអនាគត។

សម្តេចប្រធានព្រឹទ្ធសភាក៏បានថ្លែងអំណរគុណដល់ប្រជាពលរដ្ឋជាម្ចាស់ឆ្នោត ដែលស្រឡាញ់សន្តិភាព និងការអភិវឌ្ឍ ដែលបានអញ្ជើញទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ កាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២កន្លងទៅយ៉ាងសស្រាក់សស្រាំ។ ទន្ទឹមនឹងនោះ សម្តេចបានអំពាវនាវដល់ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតទាំងអស់ សូមគាំទ្រនូវបុព្វហេតុដ៏ថ្លៃថ្លា និងអញ្ជើញទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៃរដ្ឋសភានីតិកាលទី៧ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ខាងមុខឱ្យបានគ្រប់ៗគ្នា ដើម្បីជ្រើសរើសអ្នកដឹកនាំប្រទេសជាតិ ដើម្បីការអភិវឌ្ឍ និងការរីកចម្រើនរុងរឿងថ្កើងថ្កានលើគ្រប់វិស័យ៕

(អត្ថបទ៖ វ៉ាន់ ពិសិដ្ឋ និងរូបភាព៖ គង់ យ៉ារីន)

## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងចូលរួមពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣ សម្ដេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងសមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅទីព្រះស្រែ ស្ថិតក្នុងភូមិរូង ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។



❈នាល្ងាចថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ សម្ដេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខអាជ្ញាធរសង្កាត់ យុវជន នារី និងប្រជាពលរដ្ឋ នៅសង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។



❈នាថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញប្រារព្ធពិធីបួងសួងសុំសេចក្ដីសុខសប្បាយជូនប្រជាពលរដ្ឋទូទាំងប្រទេស នៅអាស្រមអ្នកតាឃ្លាំងមឿង ស្ថិតក្នុងខេត្តពោធិ៍សាត់។



# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អញ្ជើញសំណេះសំណាល ជាមួយអាជ្ញាធរស្រុកត្បូងឃ្មុំ និងក្រុងសួង ខេត្តត្បូងឃ្មុំ



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ សំណេះសំណាលជាមួយអាជ្ញាធរស្រុកត្បូងឃ្មុំ និងក្រុងសួង*

ដើម្បីពង្រឹងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ វិសហមជ្ឈការ និងតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងរដ្ឋបាលឃុំ ព្រមទាំងការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ព្រមទាំងស្តាប់នូវសំណូមពរ និងគោលការណ៍ចាំបាច់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ នាព្រឹកថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០២៣ នៅសាលាស្រុកត្បូងឃ្មុំ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដឹកនាំដោយឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានក្រុម បានអញ្ជើញជួបសំណេះសំណាលជាមួយនឹងអាជ្ញាធរឃុំថ្មពេជ្រ ឃុំជប់ ក្នុងស្រុកត្បូងឃ្មុំ និងសង្កាត់សួង សង្កាត់វិហារលួង ក្នុងក្រុងសួង ខេត្តត្បូងឃ្មុំ។

តាមរយៈការធ្វើសេចក្តីរាយការណ៍របស់អាជ្ញាធរឃុំ សង្កាត់ទាំង៤រួចមក ឯកឧត្តម **អ៊ុក ប៊ុនឈឿន** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះអាជ្ញាធរពាក់ព័ន្ធទាំងអស់ក្នុងក្រុងសួង ដែលបានចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋាន ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលធ្វើឱ្យក្រុងសួងមានការអភិវឌ្ឍជាបន្តបន្ទាប់។ ដោយឡែក អ្វីដែលអាជ្ញាធរត្រូវយកចិត្តទុកដាក់បំផុតចំពោះមុខនោះ គឺត្រូវអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាពឱ្យបានល្អប្រសើរ។ ជាមួយគ្នានោះ អាជ្ញាធរឃុំត្រូវយកចិត្តទុកដាក់ទប់ស្កាត់រាល់បញ្ហាដែលអសកម្មនៅមូលដ្ឋាន ដើម្បីការពារផលប្រយោជន៍ជូនប្រជាពលរដ្ឋឱ្យបានល្អប្រសើរឡើង ជាពិសេសត្រូវយកចិត្តទុកដាក់ក្នុងការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការនៅតាមឃុំសង្កាត់របស់ខ្លួនឱ្យបានម៉ត់ចត់ និងផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យបានល្អប្រសើរ។



*ឯកឧត្តម អ៊ុក ប៊ុនឈឿន ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២*

ក្រៅពីនេះ អាជ្ញាធរឃុំ សង្កាត់ត្រូវបន្តយកចិត្តទុកដាក់អនុវត្តតួនាទីរបស់ខ្លួនឱ្យកាន់តែប្រសើរឡើងថែមទៀត ដោយផ្តោតជាសំខាន់លើការផ្តល់សេវារដ្ឋបាល ការធ្វើសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ការងារអត្រានុកូលដ្ឋាន ការកែតម្រូវអក្ខរាវិរុទ្ធក្នុងអត្រានុកូលដ្ឋាន ការធ្វើអត្តសញ្ញាណ-




*ទិដ្ឋភាពអាជ្ញាធរចូលរួមក្នុងពិធីសំណេះសំណាល*

ប័ណ្ណសញ្ជាតិខ្មែរ មូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ និងការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព និងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេសត្រូវចូលរួមស្វែងរកដំណោះស្រាយឱ្យបានទាន់ពេលវេលាពាក់ព័ន្ធទៅនឹងបញ្ហាប្រឈម សេចក្តីត្រូវការ និងសំណូមពររបស់បងប្អូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានរៀងៗខ្លួន។

ដោយឡែកចំពោះបញ្ហាប្រឈម និងសំណូមពរដែលអាជ្ញាធរឃុំ សង្កាត់ពុំអាចដោះស្រាយបាន ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ នឹងលើកជាអនុសាសន៍ដល់អាជ្ញាធរមានសមត្ថកិច្ច មន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត ក្រសួងស្ថាប័ន អង្គភាពពាក់ព័ន្ធ និងគ្រប់យន្តការនានា ដើម្បីចូលរួមរកវិធីសាស្ត្រដោះស្រាយឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

ឯកឧត្តម **អ៊ុក ប៊ុនឈឿន** បានផ្តាំផ្ញើដល់អាជ្ញាធរមានសមត្ថកិច្ចទាំងអស់ សូមចូលរួម និងអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន សូមប្រុងប្រយ័ត្នខ្ពស់ជាប់ជានិច្ច ថែរក្សាសុខភាពកុំឱ្យឆ្លងជំងឺកូវីដ-១៩ ត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល និងទៅទទួលថ្នាំបង្ការជំងឺកូវីដ-១៩ ឱ្យបានគ្រប់ៗគ្នា។

ក្នុងឱកាសនោះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានផ្តល់ជូនដល់អាជ្ញាធរឃុំ សង្កាត់ទាំង៤ក្នុងម្នាក់ៗទទួលបានឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន១ប្រអប់។



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ថតរូបអនុស្សាវរីយ៍ជាមួយអាជ្ញាធរ*



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ផ្តល់ឧបករណ៍តេស្តរហ័សកូវីដ-១៩ ដល់ការិយាល័យសុខាភិបាលប្រតិបត្តិក្រុងសួង*

បន្ទាប់មក ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ក៏បានអញ្ជើញនាំយកឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន ២កេសធំ ស្មើនឹង៥៤ប្រអប់ ផ្តល់ជូនដល់ការិយាល័យសុខាភិបាលប្រតិបត្តិក្រុងសួងផងដែរ៕

(អត្ថបទ និងរូបភាព៖ គីម សិទ្ធី)

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ អញ្ជើញសំណេះសំណាល ជាមួយអាជ្ញាធរស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ សំណេះសំណាលជាមួយអាជ្ញាធរស្រុកស្វាយចេក*

នាព្រឹកថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ នៅវត្តវេឡុវនោ-ឡានស្វាយចេក ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បានរៀបចំពិធីសំណេះសំណាលជាមួយនឹងអាជ្ញាធរស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាពឯកឧត្តម **ប៉ុល លឹម** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ក្នុងគោលបំណង ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តច្បាប់ ដោយផ្តោតសំខាន់លើការផ្តល់សេវារដ្ឋបាល ការងារស្ថិតិប្រជាពលរដ្ឋពាក់ព័ន្ធនឹងសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ការងារអត្រានុកូលដ្ឋាន និងការកែតម្រូវអត្តរាវិរុទ្ធ ការងារមូលនិធិអភិវឌ្ឍន៍ឃុំ ការអនុវត្ត-គោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាពទាំង៧



*ឯកឧត្តម ប៉ុល លឹម ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤*

ចំណុច បញ្ហាកង្វល់ បញ្ហាប្រឈម តម្រូវការ និងសំណូមពរនានា ជុំវិញការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន។

បន្ទាប់ពីបានស្តាប់ការធ្វើសេចក្តីរាយការណ៍របស់អាជ្ញា-ធរស្រុកស្វាយចេក អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម និងសំណូមពររួចមក ឯកឧត្តម **ប៉ុល លឹម** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បានជំរុញ និងលើកទឹកចិត្តឱ្យក្រុមប្រឹក្សាឃុំ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋ-បាលឃុំ និងប្រធានភូមិ ត្រូវបន្តអនុវត្តតួនាទីរបស់ខ្លួននៅក្នុងមូលដ្ឋានឱ្យកាន់តែប្រសើរថែមទៀត ដោយផ្តោតលើការផ្តល់សេវារដ្ឋបាល ការធ្វើសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ការងារអត្រានុកូលដ្ឋាន ការកែតម្រូវអត្តរាវិរុទ្ធក្នុងអត្រានុកូលដ្ឋាន ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មូលនិធិអភិវឌ្ឍន៍ឃុំ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព បញ្ហាប្រឈម តម្រូវការ សំណូមពររបស់ប្រជាពលរដ្ឋ បន្តផ្សព្វផ្សាយការចាក់វ៉ាក់សាំងកូវីដ-១៩ បញ្ហាប្រឈមនានាពាក់ព័ន្ធលើដីធ្លី ហេដ្ឋារចនាសម្ព័ន្ធ និងបទល្មើសផ្សេងៗ។

ឯកឧត្តមប្រធានក្រុមបានសង្កត់ធ្ងន់ថា ការងារបម្រើសេវារដ្ឋបាលសាធារណៈ គឺជាការងារដ៏សំខាន់ ពីព្រោះ



*អាជ្ញាធរស្រុកស្វាយចេកឡើងរាយការណ៍*

ថា ការងារនេះនឹងស្តែងឱ្យឃើញអំពីការយកចិត្តទុកដាក់ក្នុងការអនុវត្តការងាររបស់អាជ្ញាធរមូលដ្ឋានដោយផ្ទាល់ ដែលធ្វើឱ្យប្រជាពលរដ្ឋមានភាពជឿជាក់ និងសេចក្តីទុក-ចិត្ត។ ជាងនេះទៅទៀត ការងាររដ្ឋបាលសាធារណៈក៏ជាឆ្អឹងខ្នងយ៉ាងសំខាន់មិនអាចខ្វះបាន ក្នុងការចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានផងដែរ។

ឯកឧត្តមក៏បានផ្តាំផ្ញើដល់អាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ សូមបន្តប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួននូវវិធានការសុខា-ភិបាលនានា ព្រមទាំងមានការប្រុងប្រយ័ត្នឱ្យបានខ្ពស់ចំពោះការរស់នៅជាមួយនឹងជំងឺកូវីដ-១៩ ពីព្រោះថាជំងឺកូវីដ-១៩ នៅមិនទាន់ទៅណាឆ្ងាយពីយើងនោះទេ ដរាបណាយើងមិនយកចិត្តទុកដាក់បង្ការសុខភាពខ្លួនឯង មេរោគកាចសាហាវនេះ នឹងអាចញាំញីរាងកាយយើងបានគ្រប់ពេលវេលា ព្រមទាំងចូលរួមបន្តផ្សព្វផ្សាយជំរុញការចាក់វ៉ាក់សាំងដូសជំរុញជូនដល់បងប្អូនប្រជាជនឱ្យបានគ្រប់ៗគ្នាទៅតាមការកំណត់របស់រាជរដ្ឋាភិបាលលើផែនការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩។

ឯកឧត្តមបានបញ្ជាក់ថា ចំពោះបញ្ហាប្រឈម និងសំណូម-ពរដែលអាជ្ញាធរស្រុកស្វាយចេកបានលើកឡើង ក្រុមសមា-ជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ នឹងលើកជាអនុសាសន៍ដល់អាជ្ញាធរមានសមត្ថកិច្ច និងមន្ទីរពាក់ព័ន្ធនានាជុំវិញខេត្ត ក៏ដូចជាក្រសួង ស្ថាប័នពាក់ព័ន្ធ និងគ្រប់យន្តការនានាដើម្បីចូលរួមរកវិធីសាស្ត្រក្នុងការដោះស្រាយឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

ក្នុងឱកាសនៃពិធីសំណេះសំណាលនាពេលនោះ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ក៏បាននាំយកនូវឧប-ករណ៍តេស្តរហ័សរកមេរោគកូវីដ-១៩ ប្រគល់ជូនដល់អាជ្ញា-ធរស្រុកស្វាយចេក ឃុំទាំង៨ និងមណ្ឌលសុខភាពទាំង៨។ ដោយសាលាស្រុកទទួលបានឧបករណ៍តេស្តរហ័សចំនួន២កេស ឃុំទាំង៨ ក្នុងមួយឃុំៗទទួលបាន១កេស និងមណ្ឌលសុខភាពទាំង៨ ក្នុងមួយមណ្ឌលទទួល១កេស ព្រមទាំងថវិកាមួយចំនួន៕

(អត្ថបទ និងរូបភាព៖ អ៊ុក ប៉ូលីន)





*ទិដ្ឋភាពអាជ្ញាធរស្រុកស្វាយចេកចូលរួមក្នុងពិធីសំណេះសំណាល*

# គណៈកម្មការទាំង១០ព្រឹទ្ធសភាចូលរួមកិច្ចប្រជុំនានា



❈នាព្រឹកថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម កិត្តិសេដ្ឋាបណ្ឌិត **ខា ខេឌ** ប្រធានគណៈកម្មការទី២ ព្រឹទ្ធសភាបានប្រជុំជាមួយនឹងតំណាងរាជរដ្ឋាភិបាលដឹកនាំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ស្តីពីលទ្ធកម្មសាធារណៈ និងសេចក្តីព្រាងច្បាប់ស្តីពីសារពើពន្ធ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។

❈ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបាន៖



-ដឹកនាំកិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភា (ក្រុមទី២) នៅសាលប្រជុំគណៈកម្មការទី៣ព្រឹទ្ធសភា នារសៀលថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ ដើម្បីពិនិត្យពិភាក្សាលើ៖

**១-សេចក្តីព្រាងច្បាប់ស្តីពី សារពើពន្ធ**

**២-សេចក្តីព្រាងច្បាប់ស្តីពី លទ្ធកម្មសាធារណៈ**

**៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ពាណិជ្ជកម្មតាមព្រំដែនរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម**

**៤-ការចាត់តាំងតំណាងក្រុមឡើងមានយោបល់ក្នុងសម័យប្រជុំព្រឹទ្ធសភា។**



-អនុញ្ញាតឱ្យកញ្ញាបណ្ឌិត **ស៊ូខណ្ណា ហ្គោនខ្សែត** នាយិកាប្រតិបត្តិអង្គការសម្ព័ន្ធមិត្តសត្វព្រៃ ចូលជួបសម្តែងការគួរសម ក្នុងគោលបំណងសុំអនុសាសន៍ថ្មីៗមួយចំនួន ដើម្បីរកវិធីសម្របសម្រួលធ្វើយ៉ាងណាឱ្យអង្គការអាចបន្តកម្មវិធីការពារ និងអភិរក្សព្រៃឈើក្នុងតំបន់ជួរភ្នំក្រវាញតទៅទៀត នៅសាលប្រជុំគណៈកម្មការទី៣ព្រឹទ្ធសភា នារសៀលថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣។

❈នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ព្រឹទ្ធសភាបានអនុញ្ញាតឱ្យឯកឧត្តម Jean-Baptiste

Leclére ទីប្រឹក្សាជាន់ខ្ពស់ នៃរដ្ឋសភាបារាំង ចូលជួបសម្តែងការគួរសមក្នុងឱកាសអញ្ជើញបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំគណៈ-កម្មការទី៧ព្រឹទ្ធសភា។

❋ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំ៖



-គណៈប្រតិភូសភា នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីត្រៀមចូលរួមវេទិកាថ្នាក់ដឹកនាំអាស៊ាន-កូរ៉េ ដែលគ្រោងនឹងប្រព្រឹត្តទៅនៅសប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៣ នៅកោះជេជូ នៃសាធារណរដ្ឋកូរ៉េ នៅបន្ទប់ពិសេសវិមានព្រឹទ្ធសភា នាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣។

-គណៈកម្មការទី១០ព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើរបាយការណ៍ថវិកា និងរបាយការណ៍ស្តីពី សកម្មភាពលទ្ធផលការងារប្រចាំខែឧសភា និងលើកទិសដៅការងារ-បន្ត ព្រមទាំងពិនិត្យលើបញ្ហាផ្សេងៗ នៅសាលប្រជុំ



គណៈកម្មការទី១០ព្រឹទ្ធសភា នាថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣។



❋នាថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **អោយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានដឹកនាំកិច្ចប្រជុំក្រុមមិត្តភាពព្រឹទ្ធសភាជាមួយនឹងសភាសាធារណ-រដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដើម្បីពិនិត្យពិភាក្សាការងារសំខាន់ៗ នៅសាលប្រជុំគណៈកម្មការទី៦ព្រឹទ្ធ-សភា៕

## ការទទួលពាក្យបណ្តឹង

❋នៅខែឧសភា ឆ្នាំ២០២៣ គណៈកម្មការទី១ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន២ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន៣ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន១ករណី កំពុងពិនិត្យសិក្សាចំនួន៣ករណី ឆ្លើយតបទៅម្ចាស់បណ្តឹង (ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង) ចំនួន៣ករណី និងទទួលឯកសារជូនជ្រាបដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ដើម្បីជូនជ្រាបបានចំនួន៣ករណី៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨

❈ឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ព្រឹទ្ធ-សភា បានអញ្ជើញ៖

-ចូលរួមកិច្ចប្រជុំពិភាក្សាពីផែនការសម្រាប់យុទ្ធនាការឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ និងបញ្ហាផ្សេងៗ តាមប្រព័ន្ធនិម្មិត (Zoom) ក្រោមអធិបតី-ភាពឯកឧត្តម **ឈឿន ប៊ុណ្ណារ័ត្ន** ប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានក្រុងក្រចេះ ខេត្តក្រចេះ នារសៀលថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីសម្ពោធសាលាធម្មសភា និងសមិទ្ធផលនានានៅក្នុងវត្តសម្តេចព្រះនាគវ័ន្តវរៈពោធិ៍ (ហៅវត្តសំបុក) ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅវត្តសម្តេចព្រះនាគវ័ន្តវរៈពោធិ៍ (ហៅវត្តសំបុក) ស្ថិតនៅភូមិសំបុក ឃុំសំបុក ស្រុកចិត្របុរី ខេត្តក្រចេះ នាព្រឹកថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់សមណនិស្សិត និងនិស្សិតជ័យលាភីសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋ-កិច្ចខេត្តក្រចេះ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តម-សេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើង-គោក នៅបរិវេណមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តក្រចេះ នាព្រឹកថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣។

❈ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជា ខេដ្ឋ** ប្រធានគណៈ-កម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ៖



-ចុះបំពេញទស្សនកិច្ច និងសិក្សាឈ្វេងយល់អំពីសក្តា-នុពលក្នុងវិស័យកសិកម្ម រួមមាន៖ ដំណាំកូនដើមឈើកម្រសម្រាប់ចែកជូនប្រជាជន ដំណាំដើមស្វាយ ដើមដូង ដើមក្រូចថ្លុង ដើមត្របែក និងហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀត នៅតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធីសែនជ័យ ស្ថិតក្នុងឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៣។



-ចុះសួរសុខទុក្ខលោក **វ៉ែន ខាសនា** ក្រុមការងារចុះជួយខណ្ឌឫស្សីកែវ ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន ស្ថិតនៅសង្កាត់បាក់ខែង ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់ នាយប៉ុស្តិ៍នគរបាល ស្មៀន និងមន្ត្រី នៃសង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ ដើម្បីស្តាប់ស្ថានភាពទូទៅរបស់សង្កាត់ ការអភិវឌ្ឍមូលដ្ឋានសង្កាត់ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដំណើរការសេវាជូនប្រជាពលរដ្ឋ (ការធ្វើអត្តសញ្ញាណប័ណ្ណ អត្រានុកូលដ្ឋាន...) ព្រមទាំងនាំយកនូវអង្ករចំនួន២១បាវ និងឧបករណ៍ធ្វើតេស្តរហ័សកូវីដ-១៩ ចំនួន១កេសធំ ប្រគល់ជូនរដ្ឋបាលសង្កាត់ព្រែកឯង ដើម្បីទុកចែកជូនប្រជាពលរដ្ឋក្រីក្រក្នុងមូលដ្ឋាន និងសម្រាប់

បំពេញការងារមនុស្សធម៌ផ្សេងៗ នៅសាលាសង្កាត់ព្រែកឯង រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣។

❃ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងបាននាំយកផ្លែស្វាយចែកជូនពួកគាត់ដែលកំពុងធ្វើដំណើរតាមផ្លូវសាធារណៈ នៅហាងចម្ការខ្មែរ រាជធានីភ្នំពេញ នារសៀលថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងដឹកនាំក្រុមអ្នកជំនាញបច្ចេកទេសកសិកម្ម រៀបចំសម្អាតដីសម្រាប់ដាំកូនដើមឈើរួមមាន៖ ផ្ចង់ ត្របែកព្រៃ អូយម៉ូញ សាកូរ៉ា គីនីន និងដើមរាំងទឹក សរុបចំនួន៤ម៉ឺនដើម នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងចែកជូនអាហារកញ្ចប់ និងថវិកាមួយចំនួន នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣។



-ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាជាមួយនឹងមន្ត្រី និយោជិត កម្មករ កម្មការិនី កំពង់ផែស្វយ័តក្រុងព្រះសីហនុ នាឱកាសអបអរសាទរខួបលើកទី១៣៧ នៃទិវាពលកម្មអន្តរជាតិ ១ឧសភា និងពិធីបើកការដ្ឋានសាងសង់ចំណតផែកុងតឺន័រ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចុះពិនិត្យមើលកន្លែងចុងភៅធ្វើម្ហូបសម្រាប់កម្មករក្នុងការក្សាអនាម័យ និងដឹកនាំក្រុមការងារចុះពិនិត្យមើលសកម្មភាពការងារស្ថាបនាផ្លូវឡើងភ្នំក្រាលកៅស៊ូ DBST ប្រវែង ៣.០០០ម៉ែត្រ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ និងកុមារសាលាអន្តរជាតិប៉េកាំងចំនួន២០០នាក់ មកទស្សនកិច្ចសិក្សាឈ្វេងយល់អំពីវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ម៉ុង ឫទ្ធី សែនជ័យ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងដឹកនាំក្រុមការងារបច្ចេកទេសចុះពិនិត្យដំណាំកសិកម្ម កសិ-ឧស្សាហកម្ម ហេដ្ឋារចនាសម្ព័ន្ធផ្លូវ លូ ស្ពាន ទំនប់ទឹក និងពិនិត្យមើលសមិទ្ធផលនានាក្នុងតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ព្រមទាំងដឹកនាំក្រុមអ្នកជំនាញបច្ចេកទេសកសិកម្ម រៀបចំសម្អាតដីសម្រាប់ដាំដូងក្រអូបចំនួន៦២ហិកតា ស្មើនឹង ៧៣.៣៦០ដើម នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣។

-ចុះដឹកនាំកម្មករ និងប្រជាពលរដ្ឋចូលរួមដាំដើមដូងក្រអូបចំនួន៦៥ហិកតា ស្មើនិង១៦.៥០០ដើម ព្រមទាំងចុះពិនិត្យការងារស្ថាបនាផ្លូវចាក់កៅស៊ូ DBST ប្រវែង៣.២០០ម៉ែត្រ នៅតំបន់ឆ្នេរសមុទ្រកែវផុស ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ នាព្រឹកថ្ងៃទី១៨ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខកម្មករ ព្រមទាំងចូលរួមជាមួយពួកគាត់ដាំដើមឈើព្រៃ និងដើមឈើហូបផ្លែ ចំនួន៨០.០០០ដើម ដើម្បីចូលរួមអភិរក្ស និងការពារបរិស្ថានជាមួយនឹងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា នៅភ្នំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣។

❃នាព្រឹកថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **សុខ ឥសាន** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា ឯកឧត្តម

**ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា ឯកឧត្តម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភា និងឯកឧត្តម **ទឹម ផន** លេខាធិការគណៈ-កម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីសម្ពោធអគាររដ្ឋបាលសាលាខេត្តព្រៃវែង និងអគាររោងតម្កល់ទូក-ង ដែលមានប្រវែងវែងជាងគេលើពិភពលោក ក្រោមអធិបតី-ភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយក-រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលាខេត្តព្រៃវែង។

❈លោកជំទាវកិត្តិនីតិកោសលបណ្ឌិត **ទី ម៉ូរ៉ាស៊ី** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ មណ្ឌលសុខភាពឃុំជ្រៃលាស់ និងមន្ទីរពេទ្យបង្អែកស្រុកពញាឮ ដើម្បីប្រគល់ជូននូវឱសថ និងឧបករណ៍តេស្តរហ័សកូវីដ-១៩ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន និងប្រគល់ជូនមន្ទីរ-ពេទ្យបង្អែកស្រុកពញាឮ និងមណ្ឌលសុខភាពទាំង៩ក្នុងស្រុក នូវឧបករណ៍តេស្តរហ័សកូវីដ-១៩ ចំនួន៤កេសធំ និងឱសថចំនួន៩មុខ ដែលជាអំណោយរបស់លោកជំទាវ **យក់ សម្បត្តិ** រដ្ឋលេខាធិការក្រសួងសុខាភិបាល រួមមាន៖ Acetaminophen ចំនួន២០០ដប AFD Multivitamim ៣កំប៉ុង COMegaldrox ៣កំប៉ុង Sulfame thaxazole ៣កំប៉ុង Para CPE ៣កំប៉ុង Amoxicillin ៣កំប៉ុង Hyoscine Butybromide ៣កំប៉ុង Bromhexine ៣កំប៉ុង និង Chlor phenamine ៣កំប៉ុង នៅស្រុកពញាឮ ខេត្តកណ្តាល នាថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលសួរសុខទុក្ខក្រុមប្រឹក្សាស្រុក និងឧបត្ថម្ភនូវភេសជ្ជៈចំនួន៥កេស នំចំនួន៦ប្រអប់ ម្ហូបសម្រាប់អាហារថ្ងៃត្រង់ចំនួន៣ប្រអប់ធំ និងថវិកាមួយចំនួន នៅស្រុកពញាឮ ខេត្តកណ្តាល នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ



២០២៣។



❈នាថ្ងៃទី១៣ និងថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ ឯក-ឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈ-កម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាសង្កាត់ចោមចៅទី២ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដើម្បីឈ្វេងយល់ពីសភាពការណ៍រួមក្នុងមូលដ្ឋាន ព្រមទាំងសំណូមពរឱ្យខិតខំដោះស្រាយបញ្ហាប្រឈមនានាឱ្យអស់លទ្ធភាព បន្តអនុវត្តផែនការរួមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ ឱ្យទទួលបានជ័យជម្នះ ដោយប្រើប្រាស់កម្លាំងសរុប មធ្យោបាយសរុប ធ្វើសកម្មភាពឱ្យបានព្រមៗគ្នា និងឧបត្ថម្ភថវិកាមួយចំនួន។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាល និងពិសាអាហារសាមគ្គីជួបជុំជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំអំពិលក្រៅ ស្រុកស៊ីធរ-កណ្តាល ខេត្តព្រៃវែង នាថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសាកសួរសុខទុក្ខតាមខ្នងផ្ទះប្រជាពលរដ្ឋរស់នៅឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង នាព្រឹកថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងពិធីសំណេះសំណាល និងចែកចង្ហាន់សន្សំសំចៃថាមពលជូនប្រជាពលរដ្ឋសរុបចំនួន៤៦៦គ្រួសារ (ឃុំពាំងល្វា និងឃុំភ្នំតូច) នៅក្នុងវត្តអង្គតាឯក ភូមិ



អង្គតាឯក ឃុំភ្នំតូច ស្រុកសាមគ្គីមុនីជ័យ ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៣។

-ជួបពិភាក្សាការងារជាមួយនឹងអាជ្ញាធរខេត្តស្វាយរៀង នៅសាលាខេត្តស្វាយរៀង នាព្រឹកថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០២៣។



-ដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងអាជ្ញាធរ-ខេត្ត នៅសាលាខេត្តព្រៃវែង ខេត្តព្រៃវែង នារសៀលថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០២៣។



-ជាអធិបតីភាពក្នុងពិធីសំណេះសំណាល និងចែកចង្ក្រានសន្សំសំចៃថាមពលជូនប្រជាពលរដ្ឋចំនួន២.៣៥៧គ្រួសារ នៅឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣។

❋ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមរំលែកទុក្ខជាមួយឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងក្រុមគ្រួសារ ក្នុងពិធីបុណ្យសពមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ម៉ែន សាអ៊ីន** ដែលត្រូវជាម្តាយបង្កើតឯកឧត្តមរដ្ឋមន្ត្រី ដែលបានទទួលមរណភាពដោយជរាពាធ និងព្រម-ទាំងនាំយកថវិការបស់គណៈកម្មការទី១០ព្រឹទ្ធសភាចូលបុណ្យមួយចំនួន ស្ថិតនៅក្រុងតាខ្មៅ ខេត្តកណ្តាល នារសៀលថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣។



-សួរសុខទុក្ខ និងនាំយកអំណោយជូនលោកស្រី **ចេក គីមអ៊ាង** ប្រធានអង្គការបក្សីខៀវថែទាំសុខុមាលភាពប្រជាពលរដ្ឋ ដែលទើបនឹងលំហែមាតុភាព នៅភូមិថ្មី ឃុំគ្រើល ស្រុកប្រសាទបល្ល័ង្ក ខេត្តកំពង់ធំ នារសៀលថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៣។



-ជាកិត្តិយសក្នុងពិធីសំណេះសំណាល ចែកអំណោយ និងបំពាក់គ្រឿងឥស្សរិយយសជូនដល់អតីតយុទ្ធជន និងនិវត្តជនស៊ីវិលទូទាំងស្រុកកណ្តាលស្ទឹង ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍កិត្តិបណ្ឌិត **ហ៊ីង ប៊ុនហៀង** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការ នៃបញ្ជាការដ្ឋានអង្គរក្ស នៅភូមិក្រាំងចេក ឃុំក្រាំងចេក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល នាព្រឹកថ្ងៃទី ១៤ ខែឧសភា ឆ្នាំ២០២៣។

❋ឯកឧត្តម **ខៀវ មុត** អនុប្រធានគណៈកម្មការទី១ ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាល សួរសុខទុក្ខ ចែកចង្ក្រានដាំបាយចំនួន៨៥គ្រឿង និងថវិកាមួយចំនួនជូនដល់បងប្អូនប្រជាពលរដ្ឋចំនួន៤ភូមិ គឺភូមិព្រៃឈើទាល ភូមិតាសូ ភូមិតាកឹម និងភូមិតាភេម ព្រមទាំងពិនិត្យស្រះទឹក១កន្លែង ដែលជីកដោយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ កាលពីឆ្នាំ២០១៧កន្លងទៅ ស្ថិតក្នុងឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល សួរសុខទុក្ខ ចែកចង្ក្រានដាំបាយចំនួន៩១គ្រឿង និងថវិកាមួយចំនួនជូនដល់បងប្អូនប្រជាពលរដ្ឋចំនួន៣ភូមិ គឺភូមិត្រពាំងកប្បាស ភូមិណងស្រាយ ភូមិតាគាំ សរុបចំនួន៩១គ្រួសារ និងប្រជាការពារចំនួន៩នាក់ នៅឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល សួរសុខទុក្ខ ចែកចង្ក្រានដាំបាយចំនួន៩១គ្រឿង និងថវិកាមួយចំនួនជូនដល់បងប្អូនប្រជាពលរដ្ឋចំនួន៣ភូមិ គឺភូមិម្រុំ ភូមិតាមុំ និងភូមិតាមុច និងប្រជាការពារ នៅឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣។

❉នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញចូលរួមជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមេសា និងលើកទិសដៅការងារបន្តរបស់ឃុំឫស្សីស្រុក និងផែនការឆ្ពោះទៅកាន់ការបោះឆ្នោតនាពេលខាងមុខ នៅសាលាស្រុកពាមជរ ខេត្តព្រៃវែង។



❉នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **ចាន់ ណារ៉េត** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **ណាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា លោកជំទាវ **ឃួន ឃុនឌី** សមាជិកាគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារសម្ដេចព្រះសុមេធាធិបតី **នន្ទ ង៉ែត** ១ខ្នងកម្ពស់៤ជាន់ មាន១២បន្ទប់ នៃសាខាពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងសមិទ្ធផលនានា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** នាយករដ្ឋមន្ត្រីស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា ស្ថិតក្នុងបរិវេណវត្តដំរីស ភូមិកំពង់ក្របី សង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង។

❉ឯកឧត្តម **ចាន់ ណារ៉េត** អនុប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តម **ណាំ ទុំ** លេខាធិការគណៈកម្មការទី១ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមក្នុងពិធីកាត់ឫសសីមា និងសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តសិរីមង្គល (ហៅវត្តសាមសិប) ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត**

អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក ស្ថិតក្នុងភូមិសាមសិប ឃុំតាក្រី ស្រុកកំរៀង ខេត្តបាត់ដំបង នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣។



-ចូលរួមក្នុងពិធីសំណេះសំណាលជាមួយមន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ និវត្តជន និងអតីតយុទ្ធជន ក្នុងស្រុកសំពៅលូន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្ថិតនៅបរិវេណបុរី ងិន វិត ភូមិតាស្ដា ខេត្តបាត់ដំបង នារសៀលថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣។

❋នាថ្ងៃទី៦ និងថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **ប៉ុល លឹម** អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា និងឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយនឹងមន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធ និងនិវត្តជន ក្នុងក្រុងបាត់ដំបង ស្រុកកំរៀង និងស្រុកថ្មគោល ខេត្តបាត់ដំបង។

❋ឯកឧត្តម **ឈិត គឹមយាត** អនុប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **ឌឹម លាច** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា និងលោកជំទាវ **ស៊ី វណ្ណថា** សមាជិកាគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមពិធីអបអរសាទរខួបទី១៦០ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ក្រោមប្រធានបទ “រួមគ្នាជាមួយនឹងកាកបាទក្រហមកម្ពុជា ដើម្បីបរិយាបន្នសង្គម” ព្រមទាំងនាំយកថវិកាមួយចំនួនបរិច្ចាគដល់សាខាកាកបាទក្រហមកម្ពុជាប្រចាំខេត្តកំពង់ចាម ក្រោមអធិបតីភាពឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៅសាលសន្និសីទសាលាខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល សួរសុខទុក្ខនាយប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានភូមិ និងប្រជាពលរដ្ឋ ព្រមទាំងឈ្វេងយល់អំពី ការអនុវត្តគោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការ ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន និងភូមិ ឃុំ មានសុវត្ថិភាព ព្រមទាំងបានឧបត្ថម្ភថវិកាមួយចំនួន និងឧបករណ៍តេស្តកូវីដ-១៩ ជូនដល់ឃុំ១កេស មន្ទីរពេទ្យបង្អែក និងការិយាល័យស្រុកប្រតិបត្តិកោះសូទិន ចំនួន៤កេស នៅភូមិប្រធ្នោះ ឃុំព្រែកតានង់ ស្រុកកោះសូទិន ខេត្តកំពង់ចាម នារសៀលថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមក្នុងកម្មវិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្ពានបេតុងចំនួន៩កន្លែង ស្ថិតលើកំណាត់ផ្លូវជាតិលេខ ៧0B ស្ថិតក្នុងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីបញ្ចុះខណ្ឌសីមា និងសម្ពោធដាក់ឱ្យប្រើប្រាស់សមិទ្ធផលនានា នៅវត្តសែនមនោរម្យ (ហៅវត្តចាស់) ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅភូមិ



កងតាណឹងទី៨ ឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់-ចាម នាព្រឹកថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣។

❋នាថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **ឆាយ ខន** អនុប្រធានគណៈកម្មការទី៦ព្រឹទ្ធសភាបានដឹកនាំអង្គសន្និបាតបូកសរុបសភាពការណ៍ទូទៅ និងលទ្ធផលការងារនៅមូលដ្ឋានឆ្នាំ២០២២ និងទិសដៅឆ្នាំ២០២៣ នៅខេត្តកោះកុង។

❋ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីសំណេះសំណាល និងផ្សព្វផ្សាយខ្លឹម-សារសង្ឃប្រកាសអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣០ និងសេចក្ដីសង្ឃសន្និបាតសាលាគណរាជធានីភ្នំពេញ ឆ្នាំ២០២៣ ស្ថិតនៅវត្តត្បៀតសម្ពិលី ខណ្ឌកំបូល រាជធានីភ្នំពេញ នាថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣។



-ចូលរួមប្រជុំជាមួយលោកប្រធានភូមិទាំង១៣ និងក្រុមប្រឹក្សាសង្កាត់ ដើម្បីស្ដាប់ផែនការការពារចំណុចខ្ពស់ និងការបែងចែកភារកិច្ចក្នុងការអនុវត្តគោលនយោបាយភូមិសង្កាត់មានសុវត្ថិភាព ព្រមទាំងពិនិត្យស្ថិតិប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាតជាក់ស្ដែង (ប្រភេទ ក្រ១ និងក្រ២) និងឧបត្ថម្ភអង្ករ និងថវិកាថែទាំការពារសុខភាពមនុស្សចាស់ នៅសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងមន្ត្រីផ្នែកសួនច្បារ និង



អ្នកបើកបរ ព្រមទាំងឧបត្ថម្ភកង់ចំនួន៧គ្រឿង កន្សែងពោះគោ និងថវិកាមួយចំនួន នៅមុខអគារ D2 ព្រឹទ្ធសភា នាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមពិធីរំលឹកដល់វិញ្ញាណក្ខន្ធជនរងគ្រោះជាងបី-លាននាក់ ដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត ជាការរំលឹកទិវាជាតិ នៃការចងចាំ ២០ ឧសភា ឆ្នាំ២០២៣ នៅភូមិរលួស សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០២៣។

❋ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ ព្រឹទ្ធសភាបានអញ្ជើញ៖



-នមស្ការសមាទានសីលចម្រើនព្រះបរិត្តក្នុងមហារោង និងនិមន្តព្រះសង្ឃសម្ដែងធម៌ទេសនា តតិយសង្គាយនា (ត្រៃបី) ក្នុងឱកាសពិធីបុណ្យកាត់ឫសសីមាព្រះវិហារ នៅវត្តលុម្ពិនីសាលវ៉ននារាម ហៅវត្តអូរសោម នៅភូមិអូរសោម ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ នាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល និងប្រគល់ថវិកាមួយចំនួន សម្រាប់ទិញលូ ដើម្បីដាក់បង្ហូរទឹកចេញពីផ្លូវក្នុងភូមិថ្នល់-ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល នាព្រឹកថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៣។

❈ឯកឧត្ដម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងនិស្សិតមហាវិទ្យាល័យកសិកម្ម នៃសាកលវិទ្យាល័យស្វាយរៀង នៅខេត្តស្វាយ-រៀង នាថ្ងៃទី២៨ ខែមេសា ថ្ងៃទី១២ និងថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ ដើម្បីត្រៀមរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នាពេលខាងមុខ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនរដ្ឋបាលឃុំ អ្នកចូលរួម និងគ្រួសារនៃសព នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល សួរសុខទុក្ខជាមួយនឹងប្រធានភូមិ អនុប្រធានភូមិ និងប្រជាពលរដ្ឋ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់អ្នកចូលរួម និងគ្រួសារនៃសពចំនួន៣គ្រួសារ នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងថ្នាក់ដឹកនាំខេត្ត ស្រុក ឃុំ ស្ដីពីផែនការសកម្មភាពឆ្ពោះទៅការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ នៅឃុំព្រះពន្លា ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣។

❈ឯកឧត្ដម **ម៉ែន-ស៊ីផាន់** អនុប្រធានគណៈកម្មការទី៩ ព្រឹទ្ធសភាបានអញ្ជើញ និងឯកឧត្ដម **គឹម ឆា** លេខាធិការ-គណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីបុណ្យឆ្លងឧបដ្ឋានសាលា និងសម្ពោធសមិទ្ធផលនានានៅវត្តលក្ខជា ព្រមទាំងនាំយកក្រណាត់ក្រមា និងថវិកាមួយចំនួនជូនដល់អ្នកចូលរួមផងដែរ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋ-សភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅភូមិលក្ខជា ឃុំចក ស្រុករំដួល ខេត្តស្វាយរៀង នាព្រឹកថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមពិធីផ្សព្វផ្សាយខ្លឹមសារសង្ឃប្រកាសអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី៣០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋ-សភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅសាលប្រជុំសាលាខេត្តស្វាយរៀង នារសៀលថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣។



-ជួបសំណេះសំណាល នឹងសួរសុខទុក្ខជាមួយនឹងក្រុម-ប្រឹក្សាឃុំ អាចារ្យ គណៈកម្មការវត្ត និវត្តជន និងប្រជាពលរដ្ឋ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅឃុំព្រះពន្លា ស្រុកកំពង់-រោទិ៍ ខេត្តស្វាយរៀង នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣។

❈ឯកឧត្ដម **ហែម ខន** អនុប្រធានគណៈកម្មការទី១០ ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំទាំង៣០ឃុំ របស់ស្រុកបរសេដ្ឋ ដើម្បីឈ្វេងយល់អំពីការធ្វើ និងផ្ដល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ និងការអនុវត្តគោល-នយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ព្រមទាំងនាំយកអំណោយរួមមាន៖ ក្រមា១ នំប៉ាវ១ ឧបករណ៍តេស្ដកូវីដ-១៩ ចំនួន១ប្រអប់ និងឧបត្ថម្ភថវិកាដល់មន្ត្រីឃុំដែលសម្រាកព្យាបាលជំងឺនៅគេហដ្ឋានចំនួន២នាក់ នៅសាលប្រជុំសាលាស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៩ ខែមេសា និងថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ភូមិ នៃ

ឃុំទាំង៣គឺ៖ ឃុំសំរោងទង ឃុំសំបូរ នឹងឃុំត្រពាំងគង ស្រុកសំរោងទង ដើម្បីឈ្វេងយល់អំពីការធ្វើ និងផ្តល់អត្ត-សញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ និងការអនុវត្តគោល-នយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ព្រមទាំងនាំយកអំណោយរួមមាន៖ ក្រមា១ សារុង១ ត្រីខ១កំប៉ុង នំប៉ុង២ដើម និងទឹកបរិសុទ្ធ១ដប និងឧបត្ថម្ភថវិកាមួយចំនួនដល់អាជ្ញាធរឃុំទាំង៣សម្រាប់ប្រើប្រាស់ នៅសាលប្រជុំសាលាស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៦ ដល់ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាឃុំ ភូមិ នៃឃុំក្រាំងអំពិល ដើម្បីឈ្វេងយល់អំពីការអនុវត្តគោលនយោ-បាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព និងការងារត្រៀមរៀបចំការបោះឆ្នោតនាពេលខាងមុខ ព្រមទាំងនាំយកអំណោយរួមមាន៖ ក្រមា១ សារុង១ ត្រីខ១កំប៉ុង នំប៉ុង២ដើម និងទឹកបរិសុទ្ធ១ដប នៅឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ភូមិ នៃឃុំស្គុះ ដើម្បីឈ្វេងយល់អំពីការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងការងារត្រៀមរៀបចំការបោះ-ឆ្នោតនាពេលខាងមុខ ព្រមទាំងនាំយកអំណោយរួមមាន៖ ក្រមា១ សារុង១ ត្រីខ១កំប៉ុង នំប៉ុង២ដើម និងទឹកបរិសុទ្ធ១ដប នៅឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣។



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សា ឃុំ ភូមិ នៃឃុំសែនដី ដើម្បីឈ្វេងយល់អំពីការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព និងការងារត្រៀមរៀបចំការបោះឆ្នោតនាពេលខាងមុខ ព្រមទាំងនាំយកអំណោយរួមមាន៖ ក្រមា១ សារុង១ ត្រីខ១កំប៉ុង នំប៉ុង២ដើម និងទឹកបរិសុទ្ធ១ដប និងឧបត្ថម្ភថវិកាមួយចំនួនដល់អាជ្ញាធរឃុំសម្រាប់ប្រើប្រាស់ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣។

❋លោកជំទាវ **កង សៅវ៉ែន** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ប៉ែន ស៊ីម៉ន** ប្រធានគណៈ-កម្មការទី១០រដ្ឋសភា នៅសាលសន្និសីទបូកគោ ខេត្តកំពត នាព្រឹកថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣។



-ចូលរួមពិធីបញ្ចុះខណ្ឌសីមាឆ្លងព្រះវិហារថ្មី និងសម្ពោធសមិទ្ធផលនានាក្នុងវត្តអង្គជុំស្រះឈូក ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ប៉ែន ស៊ីម៉ន** ប្រធានគណៈកម្មការទី១០រដ្ឋសភា នៅភូមិកោះទ្រមូង ឃុំបឹងសាលាខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត នាថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារ



សិក្សា៣ខ្នង មាន២១បន្ទប់ និងបញ្ចុះបឋមសិលាសាងសង់អគារសិក្សា១ខ្នង ២ជាន់ មាន១០បន្ទប់ ព្រមទាំងសំណេះ-សំណាលមន្ត្រី អាជ្ញាធរស្រុក លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ម៉ែន ស៊ីម៉ន** ប្រធានគណៈកម្មការទី១០រដ្ឋសភា នៅស្រុកដងទង់ ខេត្តកំពត នាព្រឹកថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣។

❈លោកជំទាវ **កុយ សៅផែន** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមពិធីដង្ហែ និងបុណ្យបូជាព្រះសព ព្រះពុទ្ធវង្ស **ឯម តឿង** (អតិប្បញ្ញោ) ព្រះរាជាគណៈថ្នាក់ត្រី អតីតព្រះ-មេគណខេត្តកំពត និងជាអតីតព្រះគ្រូចៅអធិការវត្តជុំគ្រៀល ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ម៉ែន ស៊ីម៉ន** ប្រធានគណៈកម្មការទី១០រដ្ឋសភា នៅវត្តជុំគ្រៀល នៅឃុំជុំគ្រៀល ខេត្តកំពត នាព្រឹកថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៣។



-ចូលរួមពិធីបញ្ចុះខណ្ឌសីមា និងសម្ពោធដាក់ឱ្យប្រើ-ប្រាស់ព្រះវិហារវត្តកែវមណីវ័ន ដែលជាព្រះវិហារទី៧៣ របស់ខេត្តកំពត និងជាព្រះវិហារទី១៧ របស់ស្រុកបន្ទាយ-មាស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត **ម៉ែន ស៊ីម៉ន** ប្រធានគណៈកម្មការទី១០រដ្ឋសភា នៅក្នុងឃុំទូកមាសខាងលិច ស្រុកបន្ទាយមាស ខេត្តកំពត នាព្រឹកថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៣។



-ចូលរួមពិធីបុណ្យសម្ពោធឆ្លងសេនាសនទាន វត្តត្រពាំង-ខ្វា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត **ម៉ែន ស៊ីម៉ន** ប្រធានគណៈកម្មការទី១០រដ្ឋសភា នៅវត្តត្រពាំង-ខ្វា ស្រុកអង្គរជ័យ ខេត្តកំពត នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣។

❈នាថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ ដើម្បីឈ្វេងយល់ពីការងារផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ បញ្ហាប្រឈម និងសំណូមពរនានា នៅខេត្តបន្ទាយមានជ័យ។

❈ឯកឧត្តម **អន ស៊ុំ** លេខាធិការគណៈកម្មការទី៤ព្រឹទ្ធ-សភា និងឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈ-កម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួម៖



-ក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា ព្រះវិហារថ្មី និងសម្ពោធសមិទ្ធផលនានាក្នុងវត្តពោធិ៍វង្សមានជ័យ (ហៅវត្តស្វាយ-ត្រស់) ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍

បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅភូមិបឹងត្រស់ ឃុំភ្នំតូច ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ នាព្រឹកថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣។



-ក្នុងពិធីទិវាជាតិ នៃការចងចាំ ២០ឧសភា ឆ្នាំ២០២៣ នៅវត្តសុភមង្គល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នារសៀលថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣។



-ចូលរួមអបអរសាទរពិធីសំណេះសំណាល និងបំពាក់គ្រឿងឥស្សរិយយសការពារជាតិ ជូនអតីតយុទ្ធជនកម្ពុជា ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី នៅក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០២៣។

❈ឯកឧត្តម **ឆាយ ថណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា និងឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញៈ

-ជាកិត្តិយសក្នុងពិធីបញ្ចុះខណ្ឌសីមាព្រះវិហារពុទ្ធាភិសេក និងសម្ពោធឆ្លងសមិទ្ធផលនានាក្នុងពុទ្ធសីមា វត្តសិលារង្សី (ហៅវត្តក្រពងថ្ងូរ) ក្រោមអធិបតីភាពឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅភូមិត្រពាំងឫស្សី ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣។



-ជាកិត្តិយសក្នុងពិធីសម្ពោធឆ្លងកុដិ អគារពុទ្ធិកវិទ្យាល័យសម្តេចតេជោ និងសមិទ្ធផលនានា នៅក្នុងវត្តវិហារទន្ទឹម ក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ជា សុផារ៉ា** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅសង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣។



❈នាព្រឹកថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **ឆាយ ថណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភា និងឯកឧត្តម **ហេង ប៊ូរ៉ា** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា ក្នុងវត្តបទុមកេសរ (ហៅវត្តខ្ពបរកាលើ) ក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ជា សុផារ៉ា** រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ។



❋នាថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **ឆាយ ថណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភាបានអញ្ជើញចុះសួរសុខទុក្ខ និងប្រជុំពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ ព្រមទាំងឧត្តម្ភថវិកាមួយចំនួនដល់ក្រុមប្រឹក្សាឃុំក្នុង១នាក់ទទួលបាន៖ សារុង១ តេស្តរហ័សកូវីដ-១៩ ចំនួន ១ប្រអប់ នៅឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

❋ឯកឧត្តម **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី១៣៧ នៃទិវាពលកម្មអន្តរជាតិថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ ក្រោមប្រធានបទ "សន្តិភាព ស្ថិរភាព មុខរបរ និងការងារ" នៅតំបន់សេដ្ឋកិច្ចពិសេស មេហាតធេនក្រុងបាវិត ដែលមានកម្មករ កម្មការិនីប្រមាណ២.០០០នាក់ និងឧបត្ថម្ភថវិកាមួយចំនួន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នៅក្រុងបាវិត ខេត្តស្វាយរៀង នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋចំនួន ១៣៤នាក់ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់រាជរដ្ឋាភិបាល និងត្រៀមលក្ខណសម្បត្តិទៅបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នៅភូមិក្រៅ ឃុំគ្រួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង នាថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣។

-ចូលរួមពិធីសំណេះសំណាលជាមួយក្រុមបេក្ខជនដែលឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ មណ្ឌលខេត្តស្វាយរៀង ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន និងសារុងចំនួន១ នៅខេត្តស្វាយរៀង នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមជាកិត្តិយសក្នុងពិធីបុណ្យទិវាជាតិ នៃការចងចាំ ២០ ឧសភា (១៩៧៩-២០២៣) គម្រប់ខួប៤៤ឆ្នាំដែលរបបកម្ពុជាប្រជាធិបតេយ្យសម្លាប់ប្រជាជនកម្ពុជាដោយអយុត្តិធម៌ នៅវត្តកំពង់ត្រាច ឃុំកំពង់ត្រាច ស្រុករមាសហែក ខេត្តស្វាយរៀង នាព្រឹកថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣។

❋ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមពិធីបញ្ចុះខណ្ឌសីមាព្រះវិហារថ្មី និងសម្ពោធឆ្លងមណ្ឌលកុមារកំព្រាវិសាខា នៃសេចក្ដីសង្ឃឹម វត្តខ្វាស់ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ស្ថិតនៅភូមិខ្វាស់ ឃុំបុស្សរូវ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី១ ខែឧសភា ឆ្នាំ ២០២៣។



-ជួបសំណេះសំណាល សួរសុខទុក្ខលោកនាយក នាយិកាទូទាំងស្រុក និងលោកគ្រូ អ្នកគ្រូបង្រៀននៅសាលាបឋមសិក្សាស្វាយចេក និងលោកគ្រូ អ្នកគ្រូពេទ្យ នៃមន្ទីរពេទ្យបង្អែកស្រុកស្វាយចេក ព្រមទាំងប្រធានមណ្ឌលសុខភាពសេវាឯកជនបន្ទប់ថៃទាំ និងពិគ្រោះព្យាបាល មន្ត្រីការិយាល័យសុខាភិបាលប្រតិបត្តិស្រុកថ្មពួក ព្រមទាំងឧបត្ថម្ភសារុង ថវិកាសម្រាប់ធ្វើផ្លូវបេតុង និងដើមឈើ និងរៀបចំពិសាអាហារសាមគ្គី នៅខេត្តបន្ទាយមានជ័យ នាថ្ងៃទី៤ ថ្ងៃទី១៤ និងថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣។

-នាំយកថវិកាមួយចំនួន ទៅប្រគល់ជូនសាខាកាកបាទក្រហម ខេត្តបន្ទាយមានជ័យ ព្រមទាំងចូលរួមក្នុងពិធីបើកវគ្គបណ្ដុះបណ្ដាលបំប៉នសមត្ថភាពជំនាញដល់មន្ត្រីភូមិ ឃុំ ចំណុះស្រុកស្វាយចេក នៅសាលប្រជុំសាលាស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី៩ ខែឧសភា ឆ្នាំ



២០២៣។



-ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាឃុំ មេបញ្ជាការកងកម្លាំងទាំង៣ និងប្រធានឃុំទាំង៨ ក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ដើម្បីផ្លាស់ប្ដូរបទពិសោធន៍គ្នាទៅវិញទៅមក អំពីការអនុវត្តច្បាប់ ការធ្វើលិខិតបទដ្ឋានគតិយុត្តដោយផ្ដោតសំខាន់លើការផ្ដល់សេវារដ្ឋបាល និងការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ព្រមទាំងការអនុវត្តផែនការរួមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ នាថ្ងៃទី១៣ ថ្ងៃទី១៥ ខែឧសភា ២០២៣។



-ចុះពិនិត្យពីស្ថានភាពការជួសជុលផ្លូវលេខ២.៥៦១ (ចាប់ពីចំណុចផ្លូវវិស្វកម្មកាត់តាមភូមិចក់ពួក ដល់ផ្លូវលេខ៥៨) ស្ថិតនៅឃុំស្លក្រាម ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣។



-ចូលរួមពិធីបិទវគ្គហ្វឹកហ្វឺនក្បាច់គុន នៃយោធពលខេមរភូមិន្ទ ចំណុះយោធភូមិភាគទី៥ និងបើកវគ្គហ្វឹកហ្វឺនជំនាញប្រឆាំងបាតុកម្ម និងក្បាច់គុន នៃយោធពលខេមរភូមិន្ទ ចំណុះកងពលតូចថ្មើរជើងលេខ៥១ នៅទីបញ្ជាការកងពលតូចថ្មើរជើងលេខ៥១ ភូមិភ្នំជញ្ជាំង ឃុំជប់វារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ នាថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមប្រជុំត្រួតពិនិត្យការងារឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ នាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣។

❈លោកជំទាវ **មុំ សណ្ដាប់** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីភាពក្នុងទិវាជាតិ នៃការចងចាំ ២០ឧសភា បង្សុកូលរាប់បាត្រព្រះសង្ឃចំនួន១៨០អង្គ និងគោរពវិញ្ញាណក្ខន្ធប្រជាជនដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបប្រល័យពូជសាសន៍ នៅមជ្ឈមណ្ឌលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជើងឯក រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមពិធីគោរពវិញ្ញាណក្ខន្ធសពឪពុកក្មេកលោកជំទាវ **មុំ ក្រសាល** សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ នៅគេហដ្ឋាននៃសព ស្ថិតនៅរាជធានីភ្នំពេញ នាល្ងាចថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣។

❈នាព្រឹកថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **ទឹម ផន** លេខាធិការគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ




ជួបសំណេះសំណាលជាមួយនឹងក្រុមប្រឹក្សាស្រុក ឃុំ អាជ្ញាធរ ព្រមទាំងនាំយកនូវឧបករណ៍តេស្តដែលជាអំណោយរបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ជូនអាជ្ញាធរស្រុកចំនួន១កេស ឃុំទាំង៨ក្នុង១ឃុំចំនួន៥ប្រអប់ និងមណ្ឌលសុខភាពទាំង៨ ក្នុង១មណ្ឌលចំនួន៥ប្រអប់ និងថវិកាមួយចំនួន នៅស្រុកកញ្ច្រៀច ខេត្តព្រៃវែង។

❋ឯកឧត្តម **ឡាន់ ឆន** លេខាធិការគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមេសា និងលើកទិសដៅការងារបន្តរបស់ក្រុមការងារចុះជួយស្រុកអូររាំងឪ នៅស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋក្នុងភូមិចំឡាក់ នៅឃុំចក ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣។

-នាំយកថវិកាមួយចំនួនប្រគល់ជូនកាកបាទក្រហមខេត្តត្បូងឃ្មុំ ដើម្បីអបអរសាទរខួបទី១៦០ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ២០២៣ ក្រោមប្រធានបទ “រួមគ្នាជាមួយកាកបាទក្រហមកម្ពុជា ដើម្បីបរិយាបន្នសង្គម” នៅសាខាកាកបាទក្រហម ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋចំនួន៤ភូមិគឺ៖ ភូមិទួលសូភី ភូមិបឹងផ្អិល ភូមិបង្កានស ភូមិទួលស្រឡៅ ស្រុកអូររាំងឪ ព្រមទាំងចុះត្រួតពិនិត្យមើលទំនប់ទ្វារទឹកទួលតាហោ និងសាកសួរសុខទុក្ខកសិករដាំជី ដាំបន្លែ នៅទំនប់ទឹកទ្វារទឹកទួលតាហោ ស្ថិតក្នុងភូមិទួលតាហោ ឃុំទួលសូភី ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣។

-ជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយនឹងតំណាងក្រុមហ៊ុនមកពីប្រទេសម៉ាឡេស៊ី ដែលមានបំណងឈ្វេងយល់អំពីនីតិវិធីផ្លូវច្បាប់ ដើម្បីទិញ និងដឹកយកសត្វគោពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសម៉ាឡេស៊ី ស្ថិតនៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣។



-ជាកិត្តិយសក្នុងពិធីបុណ្យសម្ពោធមហាកុដិ និងឆ្លងសមិទ្ធផលនានា នៅវត្តអម្ពវ័ន (ហៅវត្តស្វាយដំណាក់) ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅភូមិស្វាយដំណាក់ ឃុំជំនីក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា និងលើកទិសដៅការងារបន្តរបស់ក្រុមការងារចុះជួយស្រុកអូររាំងឪ នៅស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ នារសៀលថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣។

❋ឯកឧត្តម **ឌឹម លាច** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា និងលោកជំទាវ **ស៊ី វណ្ណថា** សមាជិកាគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីសំណេះសំណាលជាមួយនឹងកម្មករ កម្មការិនី រោងចក្រកាត់ដេរស្បែកជើងកាលីនតុន ចំនួន ៦៦៧៥នាក់ ក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ានិត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ នៅភូមិរវៀង ឃុំខ្នុរដំបង ស្រុកជើងព្រៃ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមក្នុងពិធីសំណេះសំណាលជាមួយនឹងកម្មករ កម្មការិនីរោងចក្រកាត់ដេរ CPCG ក្រោមអធិបតីភាពឯកឧត្តម **ឌិត ឌីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅភូមិឈូក ឃុំគោករវៀង ស្រុកជើងព្រៃ ខេត្តកំពង់ចាម នារសៀលថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣។

❈ឯកឧត្តម **ខឹម លាវ** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមដឹកនាំកិច្ចប្រជុំជាមួយនឹងក្រុមប្រឹក្សាឃុំ និងក្រុមការងារចុះជួយឃុំត្រពាំងគរ ដើម្បីពិនិត្យមើលលើផែនការណ៍យុទ្ធនាការឃោសនាបោះឆ្នោតនាពេលខាងមុខ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនដល់គ្រួសារសពចំនួន៤ ស្ត្រីសម្រាលកូនចំនួន៦នាក់ និងក្រុមការងារ ដើម្បីចុះធ្វើយុទ្ធនាការឃោសនាបោះឆ្នោត នៅឃុំត្រពាំងគរ ស្រុកជើងព្រៃ ខេត្តកំពង់ចាម នារសៀលថ្ងៃទី២ ខែឧសភា ឆ្នាំ ២០២៣។

❈នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **ញ៉ែម សុខ** សមាជិកគណៈកម្មការទី២ព្រឹទ្ធសភាបានអញ្ជើញ ចូលរួមជាកិត្តិយសក្នុងពិធីបុណ្យឆ្លងព្រះវិហារ សាលាឆាន់ សាលាបាលី សារមន្ទីរ ខ្លោងទ្វារ និងសម្ពោធសមិទ្ធផល នានាក្នុងវត្តហ្លួង ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តម សេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅសង្កាត់លលកស ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

❈ឯកឧត្តម **ច្រឹម គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា និងលោកជំទាវ **ស៊ី វណ្ណថា** សមាជិកាគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារ និងសម្ពោធសមិទ្ធផលនានានៅវត្តនិរោធរង្សី ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅឃុំរាយប៉ាយ ស្រុកកងមាស ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមកម្មពិធីសម្ពោធឆ្លងមហាកុដិ អគារសិក្សា និងសមិទ្ធផលនានាក្នុងវត្តមុនីរង្សី ក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ានិត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ នៅវត្តមុនីរង្សី ភូមិអូររុន ឃុំខ្ពបតាងួន ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៣។

❈ឯកឧត្តម **ច្រឹម គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីភាពក្នុងពិធីបើកកម្មវិធីពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ដោយក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់សម្តេចឧត្តមទេពញាណ **ហ៊ុន ណេង** នៅឃុំមេសរជ្រៃ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ ក្រោមអធិបតីភាពឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ានិត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ នៅឃុំខ្ពបតាងួន ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម នាព្រឹកថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣។

❈ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមប្រជុំពិភាក្សាជាមួយនឹងប្រជាពលរដ្ឋ ស្តីពីការរៀបចំពិធីសូត្រគម្ពីរអាល់គួរអាននុលការីម ថ្នាក់ជាតិលើកទី៣០ ឆ្នាំ២០២៣ នៅស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមពិធីបញ្ចុះបឋមសិលាបន្ទប់សិក្សា១ខ្នង មាន១បន្ទប់ ដែលជាជំនួយរបស់សប្បុរសជនក្រៅប្រទេស នៅភូមិម៉ាក់ប្រាង្គ ឃុំកំពង់ក្រែង ខេត្តកំពត នារសៀលថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមពិធីគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋនៅភូមិតាដិប សង្កាត់អណ្តូងខ្មែរ ខេត្តកំពត នាព្រឹកថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាល និងសួរសុខទុក្ខប្រជាពលរដ្ឋ

ព្រមទាំងបាននាំយកថវិកាមួយចំនួនឧបត្ថម្ភជូនប្រជាពល-រដ្ឋក្រីក្រដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន នៅភូមិម៉ាក់ប្រាង្គ ឃុំកំពង់ក្រែង ស្រុកទឹកឈូ ខេត្តកំពត នារសៀលថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមពិធីគោរពវិញ្ញាណក្ខន្ធសពប្រជាពលរដ្ឋនៅភូមិកំពង់ក្រែង ភូមិម៉ាក់ប្រាង ឃុំកំពង់ក្រែង ខេត្តកំពត នាថ្ងៃទី២៣ និងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣។

❈នារសៀលថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា និងឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីប្រកាសតែងតាំងបំពេញបន្ថែមសមាស-ភាពថ្នាក់ដឹកនាំ និងសមាជិក សមាជិកា សមាគមរាជសីហ៍សាខាខេត្តកំពត និងការប្រកាសផ្តល់អាហារូបករណ៍ជូនដល់យុវជនសមាគមរាជសីហ៍សាខាខេត្តកំពត នៅសាលប្រជុំសាលាខេត្តកំពត ។

❈នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា និងលោក-ជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធ-សភាបានអញ្ជើញជួបសំណេះសំណាលជាមួយនឹងបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នៃរដ្ឋសភា សម្រាប់មណ្ឌលខេត្តសៀមរាប ក្រោមអធិ-បតីភាពដ៏ខ្ពង់ខ្ពស់សម្តេចពិជ័យសេនា **ទៀ បាញ់** ឧប-នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅសាលប្រជុំសាលាខេត្តសៀមរាប។

❈ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយនឹងកម្លាំងប្រជាការពារ និងប៉ុស្តិ៍នគរបាលរដ្ឋបាល នៅឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប នាថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **ឆា ស៊ីវន្ថា**



សមាជិកក្រុមប្រឹក្សាខេត្តសៀមរាប នៅគេហដ្ឋានសព ស្ថិតក្នុងសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣។

❈ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភាបានអញ្ជើញ៖



-នាំយកថវិកាមួយចំនួនជូនដល់កាកបាទក្រហមខេត្តសៀមរាបក្នុងឱកាសអបអរខួបទី១៦០ ទិវាពិភពលោក-កាកបាតក្រហមកម្ពុជា (៨ ឧសភា) នាថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣។



-ចូលរួមក្នុងពិធីទិវាជាតិ នៃការចងចាំ ២០ឧសភា ឆ្នាំ២០២៣ នៅវត្តទេពពោធិ៍វង្ស នៅភូមិត្រពាំងសេះ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣។

❈លោកជំទាវ **ឃួន យុនឌី** សមាជិកាគណៈកម្មការ

ទី៥ព្រឹទ្ធសភាបានអញ្ជើញៈ



-ចូលរួមជាកិត្តិយសក្នុងពិធីបញ្ចុះខណ្ឌសីមា និងសម្ពោធព្រះវិហារថ្មីនៅវត្តសន្ទុកក្រៅ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅវត្តសន្ទុកក្រៅ ភូមិសន្ទុកក្រៅ ឃុំកកោះ ស្រុកសន្ទុក ខេត្តកំពង់ធំ នាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣។



-ជាគណៈអធិបតីភាពក្នុងពិធីមីទ្ទិញទិវាជាតិ នៃការចងចាំ២០ឧសភា ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិ នៃកម្ពុជា និងរាប់បាត្រព្រះសង្ឃចំនួន១០៨អង្គ ស្ថិតនៅវត្តដូងសុរិយា (ហៅវត្តក្តីដូង) ឃុំក្តីដូង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាព្រឹកថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣។



-អញ្ជើញជាគណៈអធិបតីភាពក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសការពារជាតិជូនអតីតយុទ្ធជនកម្ពុជា នៅខេត្តកំពង់ធំចំនួន២.១០៥នាក់ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា នៅអគារឡូវ គឹមសេង សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ នារសៀលថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣។

❈នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញចូលរួមជួបសំណេះសំណាលជាមួយនឹងមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងនិវត្តជន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅស្រុកបាណន ខេត្តបាត់ដំបង។

❈ឯកឧត្តម **ស្រី ថេន** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញៈ

-ជួបសំណេះសំណាល និងសួរសុខទុក្ខជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុកទ្រាំង ខេត្តតាកែវ នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២។

-ដឹកនាំកិច្ចប្រជុំជាមួយនឹងក្រុមប្រឹក្សាឃុំ ប្រធានភូមិ ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាល និងស្មៀនឃុំ ស្តីពីការត្រួតពិនិត្យលទ្ធផលការងារ និងកិច្ចការសំខាន់ៗ ដែលត្រូវអនុវត្តឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួន នៅឃុំសិង្ហ ស្រុកសំរោង ខេត្តតាកែវ នាព្រឹកថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣។

❈ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញៈ

-ចូលរួមប្រជុំបូកសរុបលទ្ធផលការងាររដ្ឋបាលខេត្ត ប្រចាំខែមេសា ឆ្នាំ២០២៣ និងទិសដៅបន្តខែឧសភា ព្រមទាំងការងារត្រៀមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ ក្រោមអធិបតីភាពឯកឧត្តមនាយឧត្តមសេនីយ៍កិត្តិសង្គហបណ្ឌិត **គន់ គីម** ទេសរដ្ឋមន្ត្រី នៅសាលា

ខេត្តឧត្តរមានជ័យ នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៣។



-ចូលរួមគោរពវិញ្ញាណក្ខន្ធសពលោក **ម៉ិញ សុខ៊ាត** និវត្តជនអតីតថ្នាក់ដឹកនាំមន្ទីរសាធារណការខេត្តសៀមរាប ត្រូវជាឪពុកបង្កើតឯកឧត្តម **ម៉ិញ បានកុសល** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានទទួលមរណភាពដោយជរាពាធ សពតម្កល់ធ្វើបុណ្យតាមប្រពៃណីព្រះពុទ្ធសាសនា ស្ថិតនៅសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមប្រជុំ ដើម្បីពិនិត្យការអនុវត្តផែនការរួមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ ឆ្នាំ២០២៣ នៅសាលប្រជុំសាលាស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ នាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣។

❈ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ ព្រឹទ្ធសភាបានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយនឹងប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ និងប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាល ដើម្បីស្តាប់របាយការណ៍ អំពីវឌ្ឍនភាពការងារខែមេសា ឆ្នាំ២០២៣ និងពិនិត្យផែនការរួមឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ ឆ្នាំ២០២៣ ព្រមទាំងឧបត្ថម្ភក្រមា និងថវិកាមួយចំនួន នៅស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៣០ ខែមេសា ថ្ងៃទី៧ និងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមជាអធិបតីភាពក្នុងពិធីប្រកាសស្តីពី ការកែសម្រួលឡើងវិញក្រុមការងារដើម្បីជំរុញអនុវត្តផែនការឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ ឆ្នាំ២០២៣ ឱ្យទទួលបានជោគជ័យ នៅសាលាស្រុកជលគិរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣។



-ចូលរួមពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារពុទ្ធិកបឋមសិក្សា ព្រះខេមរត្នេរភ្នំសន្ទូច និងសមិទ្ធផលនានាក្នុងវត្តពលិសបព្វតារាម ហៅវត្តភ្នំសន្ទូច ឯកឧត្តមនាយឧត្តមសេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក នៅឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង នាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣។

❈ឯកឧត្តម **ទេព យុទ្ធី** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖



-ជាអធិបតីភាពក្នុងទិវាជាតិ នៃការចងចាំ ២០ឧសភា

នៅស្តូបតម្កល់អដ្ឋិធាតុជនរងគ្រោះក្នុងរបបប្រល័យពូជសាសន៍ ស្ថិតនៅក្នុងវត្តកំពង់ត្រឡាច សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប នាព្រឹកថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋ និងក្រុមយុវជនកាត់សក់ ដែលបានចុះកាត់សក់ជូនប្រជាពលរដ្ឋនៅភូមិថ្មី និងភូមិកំពង់ត្រឡាច សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប នាព្រឹកថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣។

❈ឯកឧត្តម **សាយ ម្ញរិន** សមាជិកគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ជាអធិបតីភាពក្នុងពិធីបញ្ចុះខណ្ឌសីមាព្រះវិហារពុទ្ធាភិសេធ និងសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តសិលារង្សី (ហៅវត្តត្រពាំងផ្លុង) នៅភូមិត្រពាំងឫស្សី ឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣។

-ជាគណៈអធិបតីភាពក្នុងកិច្ចប្រជុំពិនិត្យគម្រោងផែនការសកម្មភាពសម្រាប់ការចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នាពេលខាងមុខ នៅឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាថ្ងៃទី១៤ ខែឧសភា ឆ្នាំ ២០២៣។

-ជួបសំណេះសំណាលជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំ និងថ្នាក់ដឹកនាំភូមិទាំង២១ភូមិ នៅឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៣។

-នាំយកអាវ-សសម្រាប់កុមារមត្តេយ្យ និងថវិកាមួយចំនួនចែកជូនកុមាររៀននៅសាលាបឋមសិក្សាពោធិ៍ព្រឹក្ស នៅភូមិពោធិ៍ព្រឹក្សកើត ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣។

❈នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៣ លោកជំទាវ **ស៊ី វណ្ណថា** សមាជិកាគណៈកម្មការទី៩ព្រឹទ្ធសភាបានអញ្ជើញជួបសំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ និងពិភាក្សាការងារជាមួយនឹងក្រុមប្រឹក្សាឃុំ នៅស្រុកជើងព្រៃ ខេត្តកំពង់ចាម។

❈នាថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **សួន លន់** សមាជិកគណៈកម្មការទី១០ព្រឹទ្ធសភា និងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញជាកិត្តិយសក្នុងពិធីដាក់ដំណើរការរោងចក្រប្រព្រឹត្តកម្មទឹកស្អាត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចពិជ័យសេនា **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅភូមិជ្រាវ សង្កាត់បុស្សក្រឡាញ់ ក្រុងសៀមរាប ខេត្តសៀមរាប។

❈លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភាបានអញ្ជើញ៖

-នាំយកថវិកាមួយចំនួនប្រគល់ជូនកាកបាទក្រហមកម្ពុជាខេត្តសៀមរាប ដើម្បីអបអរសាទរខួបទី១៦០ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ឧសភា ២០២៣ ក្រោមប្រធានបទ "រួមគ្នាជាមួយនឹងកាកបាទក្រហមកម្ពុជា ដើម្បីបរិយាបន្នសង្គម" នៅក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣។

-ចូលរួមរំលែកទុក្ខជាមួយនឹងក្រុមគ្រួសារសពលោកយាយ **សម** ដែលបានទទួលមរណភាព ដោយរោគាពាធ និងចូលបច្ច័យបុណ្យមួយចំនួន នៅភូមិបឹងដូនប៉ា សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប នាព្រឹកថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៣។

-ជាអធិបតីភាពក្នុងទិវា នៃការចងចាំ ២០ឧសភា ឆ្នាំ ២០២៣ ឧទ្ទិសផលបុណ្យដល់វិញ្ញាណក្ខន្ធជនរងគ្រោះ ដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត និងឧបត្ថម្ភថវិកាមួយចំនួនដល់អង្គពិធី ស្ថិតក្នុងបរិវេណវត្តលលៃ ភូមិលលៃ ព្រមទាំងជួបសំណេះសំណាល សួរសុខទុក្ខ លោកស្រី **នេត សារ៉ែខ** សមាជិកក្រុមប្រឹក្សាស្រុកប្រាសាទបាគង ដែលកំពុងសម្រាកព្យាបាលជំងឺនៅគេហដ្ឋាន និងឧបត្ថម្ភថវិកាមួយចំនួន នៅភូមិស្វឹង ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ

❈នារសៀលថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៣ សមាជិក សមាជិកាព្រឹទ្ធសភាចំនួន៧រូប បានអញ្ជើញចូលរួមក្នុងពិធីបុណ្យគម្រប់ខួប១ឆ្នាំ និងឆ្លងប្រាង្គព្រះចេតិយរបស់សម្ដេចឧត្តមទេពញាណ **ហ៊ុន ណេង** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** នៅភូមិអណ្ដូងច្រុះ ឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម។

❈នារសៀលថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣ សមាជិក សមាជិកាព្រឹទ្ធសភាចំនួន៣១រូប បានអញ្ជើញចូលរួមពិធីបើកព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣ នៅពហុកីឡដ្ឋានជាតិមរតកតេជោ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន**។

❈នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣ សមាជិក សមាជិកាព្រឹទ្ធសភាចំនួន៧រូប បានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាលរំលឹកខួបទី៤៥ នៃថ្ងៃបង្កើតកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** នៅសាលប្រជុំបញ្ជាការដ្ឋានអង្គរក្ស ក្រុងតាខ្មៅ ខេត្តកណ្ដាល។

❈នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣ សមាជិក សមាជិកាព្រឹទ្ធសភាចំនួន៦រូប បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សាគម្រប់៧០ យាងចូល៧១ព្រះវស្សា ថ្វាយព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះរាជទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង។

❈នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ សមាជិក សមាជិកាព្រឹទ្ធសភាចំនួន៣៣រូប បានអញ្ជើញចូលរួមពិធីបិទព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** នៅពហុកីឡដ្ឋានជាតិមរតកតេជោ។



❈នារសៀលថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ខាវ ខេង** ប្រធានគណៈកម្មការទី២ ព្រឹទ្ធសភា និងឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួមទស្សនាខ្សែភាពយន្តចំណងជើង "អប្សរា" ដែលជាស្នាព្រះហស្តរបស់សម្ដេចតាក្នុងមហោស្រពភាពយន្តបារាំងលើកទី២ ដែលរៀបចំឡើងដោយអាលីយ៉ង់ហ្វ្រង់សេ និងក្រុមមិត្តភាពបែលហ្សិកកម្ពុជា ក្រោមអធិបតីភាពព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ ធម្មិកោ**

នៅសណ្ឋាគារអង្គរសូហ្វីតែល ខេត្តសៀមរាប។

❋ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញ៖



-ចូលរួមជាកិត្តិយសក្នុងពិធីប្រកាស និងប្រគល់គោរមងារកិត្តិយស “ពុទ្ធមាមកាភិបាល” របស់អង្គការពុទ្ធសាសនិកពិភពលោក និង“បណ្ឌិតកិត្តិយស ផ្នែកមនុស្សសាស្ត្រ” របស់សាកលវិទ្យាល័យជាតិ ណេហ្គរី ប៉ាដាង ជូនសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងគោរមងារកិត្តិយស “ទីប្រឹក្សាជាន់ខ្ពស់” របស់អង្គការពុទ្ធសាសនិកពិភពលោក ជូនឯកឧត្តមនាយឧត្តមសេនីយ៍បណ្ឌិត **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការ កងទ័ពជើងគោក នៅរមណីយដ្ឋានវត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ នាថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣។



-ចូលរួមក្នុងពិធីបុណ្យទក្ខិណានុប្បទានខួបគម្រប់៣ឆ្នាំ ឧទ្ទិសមហាកុសលជូនដួងវិញ្ញាណក្ខន្ធអ្នកឧកញ៉ាព្រឹទ្ធមហាឧបាសិកាធម្មញ្ញាណវិវឌ្ឍនា **ប៊ុន ស៊ាងលី** និងមហាឧបាសក **លីន ត្រី** ដែលជាឪពុកម្ដាយបង្កើតសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** នៅវត្តចំពុះក្អែក រាជធានីភ្នំពេញ នារសៀលថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣។



-ចូលរួមជាកិត្តិយសក្នុងពិធីបុណ្យឆ្លងខួប៣ឆ្នាំម្ដាយបង្កើតសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** នៅវត្តចំពុះក្អែក រាជធានីភ្នំពេញ នាថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៣។



-ជួបបណ្ឌិត Wim Vandam មកពីប្រទេសបែលហ្ស៊ិក ដើម្បីពិភាក្សាអំពីគម្រោងបង្កើតមជ្ឈមណ្ឌលថែទាំមនុស្សចាស់ជរា នៅក្នុងតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅភោជនីយដ្ឋានYisan រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣។

-ជួបសិល្បករ និងសិល្បការិនី មកសិក្សាឈ្វេងយល់អំពីវិស័យកសិកម្ម កសិឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែន-

ជ័យ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៣។

-ចូលរួមពិធីបុណ្យគម្រប់ខួប៣ឆ្នាំ ដើម្បីឧទ្ទិសកុសលជូនដួងវិញ្ញាណក្ខន្ធឯកឧត្តម **ហ៊ឹម ឆែម** នៅបុរីប៉េងហួត បឹងស្នោ សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣។

-ជួបនិស្សិតមកពីសកលវិទ្យាល័យបាត់ដំបង មកសិក្សាឈ្វេងយល់អំពីវិស័យកសិកម្ម កសិឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឬទ្ធី សែនជ័យ នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣។



-ជួបវិនិយោគិនមកពីប្រទេសចិន និងប្រទេសជប៉ុន ដើម្បីពិភាក្សាការងារ និងរកឱកាសបណ្ដាក់ទុនវិនិយោគលើវិស័យកសិកម្ម និងកសិ-ឧស្សាហកម្មនៅព្រះរាជាណាចក្រកម្ពុជា នៅភោជនីយដ្ឋានYisan រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភាបានអញ្ជើញ៖

-ចូលរួមក្នុងជំនួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយនឹងប្រធានសហព័ន្ធនារីគុយបា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅទីស្ដីការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច នាព្រឹកថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣។

-ពិសាអាហារពេលល្ងាចជាមួយនឹងគណៈប្រតិភូសហព័ន្ធនារីគុយបា នៅភោជនីយដ្ឋានឡឺប្រេស៊ីដង់ រាជធានីភ្នំពេញ នាល្ងាចថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២២។

❈នាព្រឹកថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៣ លោកជំទាវ **ឥង សៅរ៍ធន** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីចែកវិញ្ញាបនបត្រអាហារូបករណ៍ថ្នាក់ឧត្តមសិក្សា និងក្រោយឧត្តមសិក្សា ជូនដល់សិស្សរៀនពូកែ ក្រីក្រ និងកំព្រាចំនួន៥០២នាក់ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ប៉ែន ស៊ីម៉ន** ប្រធានគណកម្មការទី១០រដ្ឋសភា នៅសាលប្រជុំធំ សាលាខេត្តកំពង់ធំ។

❈នាព្រឹកទី២៣ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **ច្រឹង គឹមស្រ៊ាន** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីបុណ្យទក្ខិណានុប្បទានដាពិស្ដារគម្រប់ខួប១០ឆ្នាំ ត្រូវជាភរិយារបស់ឯកឧត្តម **ហ៊ុន សាន** នៅខណ្ឌទួលគោក រាជធានីភ្នំពេញ។



❈នាថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **ឡៅ ឆន** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភាបានអញ្ជើញចូលរួមពិធីបុណ្យវិសាខបូជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលាបុណ្យមុខព្រះមហាសក្យមុនីចេតិយ ស្រុកពញាឮ ខេត្តកណ្ដាល៕

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមេសា និងទិសដៅការងារខែឧសភា ឆ្នាំ២០២៣




*ឯកឧត្ដម អ៊ុំ សារឹទ្ធ អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបប្រចាំខែមេសា និងទិសដៅបន្ត*

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមេសា និងលើកទិសដៅការងារសម្រាប់ខែឧសភា ឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្ដម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា នាព្រឹកថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣ ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីអនុប្រធាននាយកដ្ឋានឡើង។

មានប្រសាសន៍នាពេលនោះ ឯកឧត្ដម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានជម្រាបជូនអង្គប្រជុំអំពីសភាពការណ៍អន្តរជាតិ តំបន់ និងសភាពការណ៍ជាតិ ព្រមទាំងធ្វើការបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងខែមេសានេះថា ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក៏ដូចប្រជាជនកម្ពុជាទាំងក្នុងប្រទេស និងក្រៅប្រទេស បានចូលរួមអបអរសាទរប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ប្រព្រឹត្តទៅយ៉ាងអធិកអធម ប្រកបដោយក្ដីសប្បាយរីករាយក្រោមម្លប់សន្តិភាព។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅតែបន្តការងារអាទិភាពលើមុខងារស្នូលទាំង៣របស់ព្រឹទ្ធសភា ដោយបានរៀបចំ និងចាត់ចែងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន៤លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន២លើក បានដោយរលូន។ ដោយស្ថិតក្នុងបរិបទ នៃដំណើរឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបន្តផ្ដោតការយកចិត្តទុកដាក់ខ្ពស់លើមុខងារតំណាង ដោយបានផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាចុះបំពេញការងារតាមមូលដ្ឋានរៀងៗខ្លួន បានល្អ និងទាន់ពេលវេលា។

ចំពោះមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានរៀបចំ និងចាត់ចែងជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយគណៈប្រតិភូអន្តរជាតិ ជាពិសេសជំនួបសវនាការជាមួយនឹងនាយករដ្ឋមន្ត្រីម៉ាឡេស៊ីទទួលបានលទ្ធផលល្អ និងជាកាលានុវត្តភាពថ្មីមួយបន្ថែមទៀតក្នុងការបង្កើនកម្រិតកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ម៉ាឡេស៊ី ឱ្យកាន់តែល្អប្រសើរថែមទៀត។

សម្រាប់ខែឧសភាខាងមុខ ឯកឧត្ដមអគ្គលេខាធិការព្រឹទ្ធសភាបានណែនាំដល់ថ្នាក់ដឹកនាំ គ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវត្រៀមសព្វសារពើសម្រាប់ការងារខាងមុខ គឺជារឿងអាទិភាព ដែលគ្រប់ថ្នាក់ គ្រប់ផ្នែក គ្រប់វិស័យ ត្រូវតែខិតខំជាអតិបរមា ដើម្បីឆ្ពោះទៅរកការរៀបចំលក្ខណសម្បត្តិសព្វយ៉ាង ទាំងទីកន្លែងធ្វើការ ធនធានសម្ភារៈ បរិក្ខារបច្ចេកទេស បច្ចេកវិទ្យា និងហិរញ្ញវត្ថុមានគ្រប់គ្រាន់ក្នុងដៃ និងម្ចាស់ការលើការរៀបចំបានទាន់ពេលវេលា ដូចការគ្រោងទុក ព្រមទាំងបន្តផ្ដល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា លើមុខងារទាំង៥របស់ព្រឹទ្ធសភាឱ្យបានគ្រប់ជ្រុងជ្រោយ ប្រកបដោយប្រសិទ្ធភាពប្រសិទ្ធផល កាន់តែល្អប្រសើរឡើងថែមទៀត៕

(អត្ថបទ៖ វង់ សុជាតិ និងរូបភាព៖ គង់ យ៉ារីន)



*ទិដ្ឋភាពប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមេសា និងទិសដៅបន្ត*

# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួងមុខងារសាធារណៈ រៀបចំបាឋកថា ស្ដីពី ភាពជាអ្នកដឹកនាំ នវានុវត្តន៍ និងគុណាធិបតេយ្យក្នុងរដ្ឋបាលសាធារណៈ



*ឯកឧត្ដម ព្រុំ សុខា និងឯកឧត្ដម អ៊ុំ សារឹទ្ធ ជាគណៈអធិបតី*

នាព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សហការជាមួយនឹងក្រសួងមុខងារសាធារណៈ បានរៀបចំពិធីបាឋកថាស្ដីពី ភាពជាអ្នកដឹកនាំ នវានុវត្តន៍ និងគុណាធិបតេយ្យក្នុងរដ្ឋបាលសាធារណៈ ក្រោមអធិបតីភាពឯកឧត្ដម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា និងឯកឧត្ដម **ព្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ គ្រប់គ្រងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីថ្នាក់អនុប្រធានការិយាល័យឡើងសរុបប្រមាណជាង៣០០នាក់។

ក្នុងនាមអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកឧត្ដម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានសម្ដែងនូវការស្វាគមន៍ និងថ្លែងអំណរគុណចំពោះឯកឧត្ដម **ព្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការអញ្ជើញមកធ្វើបាឋកថា។ ការធ្វើបាឋកថា នាពេលនេះពិតជាមានសារៈសំខាន់ណាស់ សម្រាប់មន្ត្រីរាជការជាថ្នាក់ដឹកនាំ ថ្នាក់គ្រប់គ្រងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងការឈ្វេងយល់បន្ថែមទៀតពាក់ព័ន្ធនឹងការងារដឹកនាំ គ្រប់គ្រង បន្តនិរន្តរភាពការងារឱ្យកាន់តែងាយស្រួល ឆាប់រហ័ស ចំគោលដៅ និងមានប្រសិទ្ធភាពជាងមុន។ ជាពិសេសស្របតាមគោលនយោបាយគន្លឹះស្ដីពី វិទ្យាសាស្ត្រ បច្ចេកវិទ្យាទំនើប នវានុវត្តន៍ ឆ្នាំ២០២២ ដល់ឆ្នាំ២០៣០។

ឯកឧត្ដមអគ្គលេខាធិការព្រឹទ្ធសភាសង្ឃឹមថា សិក្ខាកាមទាំងអស់នឹងយកចិត្តទុកដាក់ត្រងត្រាប់ស្ដាប់ និងមានសំណួរពាក់ព័ន្ធនឹងប្រធានបទ។ ឯកឧត្ដមមានជំនឿថា សិក្ខាកាមទាំងអស់នឹងទទួលបាននូវចំណេះដឹង និងបទពិសោធន៍ថ្មីៗ ដើម្បីយកមកអនុវត្តជាមួយនឹងការងាររបស់



*ឯកឧត្ដម អ៊ុំ សារឹទ្ធ ឡើងថ្លែងសុន្ទរកថាស្វាគមន៍*




*ទិដ្ឋភាពអ្នកចូលរួមក្នុងអង្គពិធីធ្វើបាឋកថា*

ខ្លួនឱ្យកាន់តែល្អប្រសើរជាងមុន ប្រកបដោយគុណភាព ប្រសិទ្ធភាពក្នុងការបម្រើសេវាជូនសមាជិកព្រឹទ្ធសភា។

ក្នុងឱកាសនោះ ឯកឧត្ដម **ព្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានសម្ដែងនូវក្ដីរីករាយដែលបាន



*ឯកឧត្ដម ព្រុំ សុខា អញ្ជើញធ្វើបាឋកថា*

អញ្ជើញមកធ្វើបាឋកថានាពេលនោះ។ ឯកឧត្ដម បានលើកយកចំណុចសំខាន់ៗមួយចំនួន ជម្រាបជូនអង្គពិធីរួមមាន៖

**១.ភាពជាអ្នកដឹកនាំ និងនវានុវត្តន៍។ ក្នុងចំណុចទី១ នេះ ឯកឧត្ដមបានសង្កត់ធ្ងន់តើអ្វីទៅភាពជាអ្នកដឹកនាំ? អំណាច និងឥទ្ធិពល ការដឹកនាំរបៀបជាវីរជន និងការដឹកនាំរបៀបមិនតាំងខ្លួនជាវីរជន និងហេតុអ្វីបានជាការដឹកនាំចាំបាច់ត្រូវមាននវានុវត្តន៍?។**

**២.គុណាធិបតេយ្យ។**

**៣.កំណែទម្រង់រដ្ឋបាលសាធារណៈ។**

**៤.តួនាទីរបស់រាជរដ្ឋាភិបាល ផ្ដោតលើកំណែទម្រង់រដ្ឋបាលសាធារណៈ ផ្លាស់ប្ដូរតួនាទីរបស់រាជរដ្ឋាភិបាល ការវិវឌ្ឍនៃសម័យកាលបដិវត្តន៍ឧស្សាហកម្ម និងរាជរដ្ឋាភិបាលឌីជីថល៕**

(អត្ថបទ៖ វ៉ាន់ ពិសិដ្ឋ និងរូបភាព៖ គង់ យ៉ារីន)



*ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងថ្នាក់ដឹកនាំក្រសួងមុខងារសាធារណៈ ថតរូបអនុស្សាវរីយ៍នៅខាងមុខអគារក្រហមព្រឹទ្ធសភា*

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការពិនិត្យវាយតម្លៃសមត្ថភាពមន្ត្រីរាជការដើម្បីតែងតាំងមុខតំណែងក្នុងអង្គការលេខ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំអំពីការងារកិច្ចការសង្គម នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គនាយិកា នៃអគ្គនាយកដ្ឋានទាំង៥ និងលោកជំទាវអគ្គាធិការ នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **អ៊ុំ សារឹទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំស្តីពី នីតិវិធី នៃការបើកផ្តល់ប្រាក់ឧបត្ថម្ភសេវាធ្វើដំណើរ និងសេវាទំនាក់ទំនងដល់មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។



❈នាព្រឹកថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងដំណើរការប្រឡងប្តូរប្រភេទក្របខ័ណ្ឌ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីពិនិត្យពិភាក្សាអំពីកាលបរិច្ឆេទប្រឡងប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបញ្ហាផ្សេងៗ នៅសាលប្រជុំពិសេសជាន់ក្រោម។



❈នារសៀលថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី កិច្ចការសភា(ជំហាន៧) សម្រាប់មន្ត្រីរាជការមានឋានៈអនុប្រធាននាយកដ្ឋានចំនួន២៦៦នាក់ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ








❈នាព្រឹកថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **លីម ប៊ុនហុក** អគ្គលេខាធិការរងព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញដាក់កូរោនផ្កា គោរពវិញ្ញាណក្ខន្ធសពលោក **ឯក ថា** ប្រធានការិយាល័យបែបបទ នៃនាយកដ្ឋានពិធីការ នៃអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅវត្តទួលសន្តិវ័ន សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

❈នាព្រឹកថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **កែវ ចាន់ណា** អគ្គនាយកនៃអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ បានអញ្ជើញធ្វើបទឧទ្ទេសនាមក្នុងវគ្គបណ្តុះបណ្តាលស្តីពី ការចែករំលែក និងបទពិសោធន៍លើការងារព័ត៌មាន និងការផ្សព្វផ្សាយក្នុងបរិបទឌីជីថល នៅនាយកដ្ឋានព័ត៌មានវិទ្យា។

❈នាព្រឹកថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **កែវ ចាន់ណា** អគ្គនាយក នៃអគ្គនាយកដ្ឋានព័ត៌មាន និងទាក់ទំនងសាធារណៈ បានអញ្ជើញបិទវគ្គបណ្តុះបណ្តាលស្តីពី ការចែករំលែក និងបទពិសោធន៍លើការងារព័ត៌មាន និងការផ្សព្វផ្សាយនៅក្នុងបរិបទឌីជីថល នៅនាយកដ្ឋានព័ត៌មានវិទ្យា។

❈នាព្រឹកថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **ឈឹម ព្រះខ័ន** ជំនួយការឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការកសាងផែនការយុទ្ធសាស្ត្រ ៣ឆ្នាំរំកិល និងគម្រោងថវិកាប្រចាំឆ្នាំ២០២៤ របស់ព្រឹទ្ធសភា នៅសាលប្រជុំពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។

❈នាល្ងាចថ្ងៃថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា បានអញ្ជើញនាំយកថវិការបស់សម្តេចប្រធានព្រឹទ្ធសភា ចូលរួមបុណ្យគម្រប់ខួប៧ថ្ងៃ ឧទ្ទិសកុសលជូនចំពោះវិញ្ញាណក្ខន្ធឧបាសក **ចាន់ឌី** ឪពុកចិញ្ចឹមរបស់ឯកឧត្តម **ព្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

❈នាល្ងាចថ្ងៃសុក្រ ទី១៩ ខែឧសភា ឆ្នាំ២០២៣ លោកជំទាវ **សាយ ចាន់ណាក់** នាយិការងខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា បាននាំយកថវិការបស់សម្តេចប្រធានព្រឹទ្ធសភា ចូលរួមរំលែកទុក្ខសពលោកស្រី **អេង សុគន្ធារី** នៅវត្តឧណ្ណាឡោម ដែលស្ថិតនៅសង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ៕

